សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការរួបរួមគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទៅវិញទៅមក - សាមគ្គីភាព

២៤

# ទស្សនាវដ្តី គ្រូបង្រៀន




ខែ កក្កដា - សីហា - កញ្ញា ឆ្នាំ ២០០៥
ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១៦៨៦ មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦

# មាតិកា

| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| ២ | ការចាត់តាំងការងាររបស់អ្នកគ្រប់គ្រង | ២ |
| | **ខប្បធម៌ទូទៅ** | |
| ៣ | ប្រវត្តិព្រះគណេស និងការគោរព | ៦ |
| ៤ | ទំនៀមទំលាប់ប្រពៃណីខ្មែរស្តីពីការអប់រំចរិយាសម្បត្តិ | ៨ |
| ៥ | អំពីចំណេះ | ១០ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | ភាពទូទៅនៃការធ្លាក់ចុះក្នុងការសិក្សារបស់កុមារ | ១៣ |
| ៧ | ក្មេងមានះម្នាក់ (ការអប់រំពីសម័យសតវត្សទី១៨) | ១៥ |
| | **វិទ្យាសាស្ត្រ និងពត៌មានវិទ្យា** | |
| ៨ | តួលេខពតិមានទូរគមនាគមន៍ | ១៧ |
| ៩ | ភាសាដែលប្រើប្រាស់ច្រើនជាងគេនៅលើពិភពលោក | ១៨ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ១០ | គោលបំណងនៃការអប់រំសីលធម៌ | ១៩ |
| ១១ | វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរនៅបឋមសិក្សាបំពេញវិជ្ជាពី ឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ | ២១ |
| ១២ | ល្បែងគណិតវិទ្យាពិសេស | ២៤ |
| ១៣ | ភូមិវិទ្យា : ប្រជាជនពិភពលោក | ២៧ |
| ១៤ | ភាសា : ឃាតកៈ ឃាតករ? | ២៨ |
| ១៥ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣១ |
| | **នាទីកំសាន្ត និង កំសាន្ត** | |
| ១៦ | បណ្តាំអ្នកម្តាយ | ៣៣ |
| ១៧ | ភ្នំចង្ក្រានរយ | ៣៥ |
| ១៨ | គុណសម្បត្តិ ១០ ប្រការ | ៣៨ |
| | **វេជ្ជសាស្ត្រ** | |
| ១៩ | រោគសន្លាក់ឆ្អឹង | ៣៩ |
| | **ពត៌មាន** | |
| ២០ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេ...? | ៤៣ |
| ២១ | ចំនួនសាលារៀន,ថ្នាក់រៀន,សិស្ស និងបុគ្គលិកសិក្សា២០០៤-០៥ | ៤៤ |
| ២២ | ស្ថិតិសពខែមេសា-ឧសភា-មិថុនា ២០០៥ | ៤៥ |
| ២៣ | ហេតុអ្វីតួនាទីសេដ្ឋកិច្ចរបស់ស្ត្រីត្រូវបានគេទុកអោយនៅក្រៅស្ថិតិ? | ៥១ |

**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណាវុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សុលីដា
- លោកស្រី ធន់ សុកុំ
- លោក ប៉ែន សារុន
- សមាជិក-សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អាង
- លោកជំទាវ ហួរ ស៊ីរី
- លោកបណ្ឌិត អ៊ឹម កុច
- លោក ស៊ិន ស៊ីម
- លោក ស៊ុង វ៉ាន់ថន
- លោក សួង សារុន

**វិចិត្រករ**

លោក ចាន់ ត្រា

**ការីកុំព្យូទ័រ**

ក. ម៉ៃ សុធី

**រូបខាងក្រៅ**

- **ពីមុខ:** ពិធីសម្ពោធផ្ទះគ្រូបង្រៀន ក្រុងព្រះសីហនុ
- **ពីក្រោយ:** កូនស្រីរបស់មន្ត្រីខ្មែរនៅចុងសតវត្សទី១៩

**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

កំពត : ០១២ ៨៥៦ ៧២២, ភ្នំពេញ : ០១២ ៨៩៧ ១៧៧, ក្រុងព្រះសីហនុ : ០១២ ៦៩៩ ៥៦០

# វិចារណកថា

ចំពោះមុខ មនុស្សជាតិកំពុងប្រឈមនឹងភាពក្រីក្រដែលបណ្ដាលមកពីកត្តាច្រើនបែបច្រើនយ៉ាងដូចជា កំនើនប្រជាជនឆាប់រហ័ស គ្រោះធម្មជាតិញឹកញាប់មានជាអាទិ៍ ទឹកជំនន់ ភាពរាំងស្ងួត ភាពរិចរិលដីដំណាំ បញ្ហាសុខភាព កត្តាសមត្ថភាពមនុស្សខ្លួនឯង ហើយពិសេសការកសាងគ្រួសារ។ ក្នុងករណីចុងក្រោយនេះ ខ្មែរយើងមិនសូវបានចាប់អារម្មណ៍ប៉ុន្មានទេ ដូចជាបញ្ហាការកសាងគ្រួសារ ដោយរៀបអាពាហ៍ពិពាហ៍កូនចៅនៅក្មេងពេក រឺរៀបទៅតាមកាមតំរេករបស់កូនចៅ ដែលពុំទាន់មានសញ្ញាណអំពីគ្រួសារបណ្ដាលអោយស្ថានភាពគ្រួសារទៅអនាគតពុំមានរស្មី ជួបការលំបាកទីទ័លក្រជាដើម។ យើងគួរទុកអោយយុវជនចេះធ្វើការសំរេចចិត្តដោយខ្លួនឯង ប្ដេជ្ញាធានាទទួលខុសត្រូវដោយផ្ទាល់ ព្រោះថាគ្រួសារជាកោសិការស់របស់សង្គម ។ សង្គមត្រូវតែយកចិត្តទុកដាក់លើបញ្ហានេះ។

បច្ចុប្បន្ននេះ យើងឃើញប្រទេសជាច្រើនបានតាក់តែងច្បាប់អាពាហ៍ពិពាហ៍ ហើយអង្គការសហប្រជាជាតិក៏បានបង្កើតមូលនិធិមួយសំរាប់ប្រជាករនេះ : មូលនិធិអង្គការសហប្រជាជាតិដើម្បីប្រជាករ (UNFPA) ។ អង្គការនេះបានធ្វើសកម្មភាពយ៉ាងទូលំទូលាយ ក្នុងនោះក៏បានសហការរៀបចំចងក្រងមេរៀនសំរាប់បញ្ចូលជាមុខវិជ្ជាមួយនៅក្នុងសាលារៀន (EMP = Enseignement en matière de la population) ដោយដាក់ស្ដែងបានលើកកត្តាជោគជ័យ ៩ យ៉ាងសំរាប់អាពាហ៍ពិពាហ៍ ÷

១- សុខភាពកាយ និងចិត្ត
២- ប្រភពចំណូល
៣- សេចក្ដីសំរេចចិត្តដើម្បីកសាង
៤- គំរប់អាយុអាពាហ៍ពិពាហ៍
៥- លំនឹងចិត្តរំភើប
៦- ការស្រលាញ់មួយទល់នឹងមួយ
៧- មានហេតុផល
៨- ការយល់ច្បាស់រវាងប្ដីប្រពន្ធ
៩- ការកសាងផែនការគ្រួសារ

ក្នុងលទ្ធិព្រះពុទ្ធសាសនា ការរកគូស្រករក៏មានគោលធម៌ ៤ ប្រការដែរ ដែលហៅថាសមជីវធម៌ ជាធម៌ដែលធ្វើអោយស្វាមីភរិយារស់នៅជាមួយគ្នាដោយសុខដុមជារៀងរហូតនោះគឺ : ១-សមសទ្ធា, ២-សមសីលា, ៣-សមចាគា, ៤-សមបញ្ញា។

ជោគជ័យក្នុងជីវិតអាពាហ៍ពិពាហ៍ ក៏ជាគោលដៅមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ស្របទៅតាមលក្ខខណ្ឌនៃប្រទេសកម្ពុជាយើង។

**គណៈកម្មាធិការនាយក**

# ការចាត់តាំងការងាររបស់អ្នកគ្រប់គ្រង ការិយាល័យ ស្ថាប័ន (តចប់)

## ៣. ការរៀបចំប្រជុំ

ក- *ពេលរៀបចំធ្វើគំរោងប្រជុំ ចាំបាច់ត្រូវពិនិត្យមើលប្រការដូចខាងក្រោម ដោយអនុវត្តនូវសំណួរ:*

- ព្រោះអ្វី ?

  តើហេតុអ្វីបានជាអ្នករៀបចំការប្រជុំ ?

  - ត្រូវកំណត់គោលបំណងអោយបានច្បាស់លាស់ ។

- អំពីអ្វី ?

  តើអ្នកនឹងធ្វើអ្វីនៅក្នុងការប្រជុំ ?

  - ត្រូវបង្កើតរបៀបវារៈ ?

- នរណាខ្លះ ?

  តើនរណាដែលអ្នកចង់អញ្ជើញអោយចូលរួមការប្រជុំ ?

  - ត្រូវកំណត់អ្នកចូលរួមប្រជុំអោយបានច្បាស់លាស់ឆ្លើយតបគោលបំណងអង្គប្រជុំ ។

- កន្លែងណា ?

  តើអ្នកនឹងធ្វើការប្រជុំនៅកន្លែងណា ?

  -ត្រូវកំណត់ទីកន្លែងអោយបានច្បាស់លាស់ ពិតប្រាកដនិងរៀបចំបំរុងបន្ទប់ប្រជុំ តុកៅអី សំភារៈពាក់ព័ន្ធ

- ពេលណា ?

  តើការប្រជុំនឹងផ្តើមនៅពេលណា ? និងបញ្ចប់នៅពេលណា ?

  - ត្រូវសំរេចចិត្តថា ចំណាយពេលប៉ុន្មានទៅលើរបៀបវារៈនីមួយៗ ។

- របៀបណា ?

  តើអ្នកនឹងធ្វើយ៉ាងណា ដើម្បីអោយការប្រជុំមានភាពរីករាយ សំរេចគោលបំណង និងបញ្ចប់តាមកាលកំណត់ ។

  - ត្រូវផ្តល់អាហារភេសជ្ជៈ សំរាប់ពិធីបិទ ដើម្បីលើកទឹកចិត្តអ្នកចូលរួម ។

ខ- *ដំណាក់នៃការរៀបចំការប្រជុំ*

- រៀបចំលិខិតអញ្ជើញ និងភ្ជាប់ជាមួយរបៀបវារៈអង្គប្រជុំ
- រៀបចំកន្លែងអង្គប្រជុំ : តុ កៅអី អគ្គីសនី ឧបត្ថម្ភ ... សំភារៈចាំបាច់មួយចំនួនទៀត
- រៀបចំកន្លែងពេលសំរាក : អាហារ កាហ្វេ ចំណី បន្ទប់អនាម័យ...។

គ- *របៀបរៀបចំបន្ទប់ប្រជុំ*

ការរៀបចំត្រឹមត្រូវ និងមានប្រសិទ្ធភាព លុះត្រាណាតែអ្នកចូលរួមមើលឃើញគ្នាទៅវិញទៅមក និងម្យ៉ាងទៀត មានបរិយាកាសគួរអោយទាក់ទាញអារម្មណ៍ ។

ឧទាហរណ៍ : ខាងក្រោមជារបៀបរៀបតុសំរាប់ការប្រជុំ ។

**បែបរង្វង់គ្មានតុ**



**ជុំវិញតុមូល**



**បែបតុបួនជ្រុងស្មើ**



**បែបតុបួនជ្រុងទ្រវែង**



**បែបតុរាងអក្សរ U**



**រៀបចំការប្រជុំដោយមានលៀងសាយភោជន៍**



## ៤. ការដឹកនាំអង្គប្រជុំ

**ក. តួនាទីរបស់អ្នកចូលរួមអាចចែកចេញជា បី ប្រភេទ :**

<u>តួនាទីរបស់ប្រធានអង្គប្រជុំ</u>

១. ទទួលខុសត្រូវលើការកំណត់របៀបវារៈ ដែលធ្វើអោយអ្នកចូលរួមដឹងច្បាស់ពីខ្លឹមសារ កាលបរិច្ឆេទ ពេលវេលា ទីកន្លែង

២. កំណត់ចំនួនចាំបាច់អ្នកចូលរួមក្នុងអង្គប្រជុំ

៣. បើកអង្គប្រជុំតាមពេលកំណត់ និងប្រកាសសមាសភាពចូលរួម

៤. ចាត់តាំងលេខាកត់ត្រា ប្រសិនបើមិនទាន់មាន

៥. ត្រួតពិនិត្យប្រធានបទ និងកំណត់ពេលវេលាសំរាប់ប្រធានបទនីមួយៗ

៦. បញ្ចៀសបញ្ហាដែលនាំអោយមានការចាកប្រធាន

៧. ធ្វើអោយអ្នកបញ្ចេញមតិចេះគោរពពេលវេលារបស់ខ្លួន

៨. សង្ខេបចំណុចសំខាន់ និងទាញសេចក្តីសន្និដ្ឋាន

៩. ប្រកាសអោយដឹងពីកាលបរិច្ឆេទប្រជុំលើកក្រោយចំពោះករណីណាមួយដែលត្រូវអនុវត្ត

១០. ប្រកាសបិទអង្គប្រជុំ

១១. ចុះហត្ថលេខាលើកំណត់ហេតុ

<u>តួនាទីរបស់សមាជិកអង្គប្រជុំ</u>

- ស្តាប់មតិយោបល់របស់សមាជិកដទៃទៀត
- បញ្ចេញមតិ
- ធ្វើតាមគំរោងការអង្គប្រជុំ
- ចូលរួមចំណែកក្នុងការសំរេច
- ជួយអោយអង្គប្រជុំដើរទៅមុខសំរេចវត្ថុបំណងអង្គប្រជុំ

<u>តួនាទីលេខាកត់ត្រា</u>

- ជួនកាលត្រូវទទួលបន្ទុកបែងចែកកំណត់ហេតុប្រជុំលើកមុន និងរបៀបវារៈអង្គប្រជុំថ្មី
- ធ្វើកំណត់ហេតុអង្គប្រជុំ
- អានកំណត់ហេតុមុននឹងបញ្ចប់អង្គប្រជុំ
- សរសេរកំណត់ហេតុក្រោយពេលប្រជុំ និងចែកជូនសមាជិកអង្គប្រជុំ
- ចុះហត្ថលេខាលើកំណត់ហេតុ និងសុំហត្ថលេខាប្រធានអង្គប្រជុំ

## ខ. របៀបធ្វើអោយអង្គប្រជុំខ្លី ឬត្រឹមត្រូវតាមកាលកំណត់

- ប្រកាសពេលវេលាដែលត្រូវចាប់ផ្តើម និងត្រូវបញ្ចប់
- កំណត់របៀបវារៈតាមពេលវេលាជាក់ស្តែង
- ម្នាក់ៗត្រូវគ្រោងកិច្ចការសំរាប់របៀបវារៈនីមួយៗ
- កំណត់ពេលវេលាសំរាប់សំរាក
- ធ្វើអោយសំរេចវត្ថុបំណងនៃអង្គប្រជុំតាមកាលកំណត់
- ត្រៀមគំនិតសំរាប់បញ្ហាដែលដោះស្រាយមិនរួច

## គ. លំនាំដែលពាក់ព័ន្ធនឹងអង្គប្រជុំ

- ការលើកទឹកចិត្ត
- ការអនុញ្ញាតអោយចូលរួមមានមតិ
- ការបញ្ឈប់ការជជែកខុសខ្លឹមសារ រឺអូសបន្លាយពេលវេលា
- ការស្តាប់ និងយកជាគំនិត
- ការអោយយោបល់ពីម្នាក់ទៅម្នាក់
- ការបង្ហាញពីគំនិតរបស់អង្គប្រជុំទាំងមូល
- ការបន្ថយភាពតានតឹងដោយបញ្ចូលភាពរីករាយ
- ការសំរុះសំរួលបញ្ហា

## ឃ. ចំណុចដែលគួរជៀសវាងក្នុងអង្គប្រជុំ

សមាជិកម្នាក់ៗដែលបានចូលរួមប្រជុំ គឺជាអ្នកមានគំនិតដ៏ល្អៗត្រៀមលក្ខណៈធ្វើអោយសំរេចវត្ថុបំណងអង្គប្រជុំ ។ ដូចនេះ ទន្ទឹមនឹងអ្វីៗដែលចង់អោយបានសំរេចនោះ ក៏យើងត្រូវដឹងពីចំណុចអសកម្មមួយចំនួនដូចខាងក្រោមៈ

- ការរំលោភបំពាន
- ការបញ្ឈប់គេមិនអោយមានមតិ
- ការនិយាយខុសរបៀបវារៈ
- ការប្រកួតប្រជែង

- ការព្យាយាមធ្វើអោយគេចាប់អារម្មណ៍មកលើខ្លួន
- ការសើចខុសរបៀប ឬសើចបញ្ឈឺ
- ទង្វើអ្វីផ្សេងមិនស្តាប់អង្គប្រជុំ ឬការដើរចេញពីអង្គប្រជុំ

## ង. កំណត់ហេតុអង្គប្រជុំ

កំណត់ហេតុអង្គប្រជុំ គឺជាឯកសារផ្លូវការដែលកត់ត្រាដំណើរការនៃការពិភាក្សា ការពិគ្រោះយោបល់ និង រាល់សេចក្តីសំរេចដែលបានដាក់ចេញដោយអង្គប្រជុំ ។ កំណត់ហេតុ គឺជាសេចក្តីថ្លែងយ៉ាងប្រាកដអំពីអ្វីដែលកើតមាន ឬអ្វីដែលបាននិយាយ ។

អ្នកកត់ត្រាត្រូវមានភារកិច្ចពីរយ៉ាងគឺ ការស្តាប់ និងការកត់ត្រា ។ ដើម្បីធានាអោយបាននូវប្រសិទ្ធភាព អ្នកកត់ត្រាកំណត់ហេតុត្រូវការ :

- ស្តាប់អោយដឹងពីហេតុការណ៍ និងគំនិត
- ស្តាប់អោយដឹងពីការយល់ព្រម ឬមិនយល់ព្រម
- កំណត់អោយឃើញពីចំណុចផ្លាស់ប្តូរ
- ធ្វើអន្តរាគមន៍ ដើម្បីអោយកាន់តែច្បាស់លាស់
- ស្នើសួរប្រសិនបើមិនបានយល់ពីអ្វីដែលបានសំរេចចិត្ត
- ធ្វើការសង្ខេបប្រការនីមួយៗ និងកត់ត្រាមុនពេលឆ្លងទៅចំណុចមួយទៀត

## ច. ការសរសេរកំណត់ហេតុ

កំណត់ហេតុគប្បីបញ្ចូលចំណុចសំខាន់ៗដូចតទៅ :

- ឈ្មោះការិយាល័យស្ថាប័ន
- កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង
- គោលបំណង
- ឈ្មោះប្រធានអង្គប្រជុំ
- ឈ្មោះសមាជិកវត្តមាន និងអវត្តមានរួមទាំងមូលហេតុ
- សង្ខេបយោបល់ និងឈ្មោះអ្នកផ្តល់មតិ
- បញ្ជាក់លទ្ធផលនៃអង្គប្រជុំ
- ឈ្មោះ និងហត្ថលេខារបស់អ្នកកត់ត្រាខាងស្តាំដៃ
- ឈ្មោះ និងហត្ថលេខារបស់ប្រធានអង្គប្រជុំខាងឆ្វេងដៃ ។

**ដកស្រង់ដោយលោក : ឆេង ឡឿន**

**ប្រធានការិ.អប់រំ និងគ្រប់គ្រងនៃវិទ្យាស្ថានជាតិអប់រំ**




# ប្រវត្តិព្រះគណេស (១) និងការគោរព

សង្គមខ្មែរជាសង្គមមួយពោរពេញទៅដោយជំនឿ និងការគោរពរបស់មនុស្សគ្រប់វ័យ និងគ្រប់វណ្ណៈ ។ ជំនឿ និងការគោរពគឺជាវិធីសាស្ត្រមួយដើម្បីជួយបន្ធូរអារម្មណ៍របស់មនុស្សឆ្ពោះទៅរកក្ដីសង្ឃឹមក្នុងជីវិត ក្នុងករណីណាគេម្នាក់ៗមានបញ្ហាក្នុងជីវិតប្រចាំថ្ងៃ ។

សាសនាក៏ជាប្រភពនៃជំនឿ និងការគោរពរបស់មនុស្សជាយូរយារមកហើយ ។ យ៉ាងណាមិញ ព្រាហ្មណ៍សាសនា ជាសាសនាចំណាស់មួយមានកំណើតនៅលើទឹកដីប្រទេសឥណ្ឌាប្រមាណជា ១៥ ០០០ឆ្នាំមុនគ.ស ។ សាសនានេះបានហូរចូលទឹកដីកម្ពុជាប្រមាណសតវត្សទី ១ នៃគ.ស ហើយបានជះឥទ្ធិពលយ៉ាងខ្លាំងក្នុងស្រទាប់បេះដូងប្រជាជនខ្មែររហូតដល់សព្វថ្ងៃនេះ ។

នៅក្នុងសាសនាព្រាហ្មណ៍មានអាទិទេព និងសត្វជាច្រើនដែលជាទីសក្ការៈបូជាសំរាប់ប្រជាជនខ្មែរ ក្នុងនោះមានព្រះគណេសជាទេវតាមានក្បាលជាដំរីជាបុត្រព្រះឥសូរដែលគេចាត់ទុកជាព្រះមួយអង្គសំរាប់គោរពសក្ការៈបូជា ។

**តើព្រះគណេសមានប្រវត្តិដូចម្ដេចខ្លះ ?**

**១- ប្រវត្តិព្រះគណេស**

ព្រះគណេស ជាកូនព្រះឥសូរ ។ នៅប្រទេសកម្ពុជាគេហៅថា គណេស ឬគេហៅថាអ្នកគណេស ព្រោះព្រះអង្គជាឆ្មាំការពារ ។ នៅក្នុងរឿងរាមកេរ្តិ៍ព្រះគណេសដើរតួជាអ្នកការពារក្រុងលង្កាដែលមានក្បាលដំរីខ្លួនជាមនុស្ស ។ គ្រូមន្តអាគមព្រះគណេសត្រូវគេហៅថា សិទ្ធិសួសមានន័យថា ជោគជ័យ និងមហាថាមពល ។ ដូច្នេះ នៅក្នុងចំណោមអាទិទេពព្រាហ្មណ៍សាសនា ព្រះគណេសមានប្រជាប្រិយភាពខ្លាំងក្លាណាស់ដែលទទួលការគោរពបូជា តាំងពីមុនសម័យអង្គររហូតដល់សព្វថ្ងៃនេះ ។ ប្រជាប្រិយភាពនេះ ត្រូវបានគេបញ្ជាក់តាមសិលាចារិកដែលគេបានប្រទះឃើញដល់សព្វថ្ងៃ ។

(១) គណេស : ឈ្មោះទេវតាមានក្បាលជាដំរី ជាបុត្រព្រះឥសូរ ។ ក្លាយមកពីពាក្យ វិឃ្នេស វិឃ្នេស្វរៈ ហើយខ្មែរច្រើនប្រើជាភឃ្នេស ។

### ២_ លក្ខណៈបដិមារបស់ព្រះគណេស

បដិមាព្រះគណេស មានរចនាអំពីថ្មជាពីររូបភាព :

- អង្គុយពែនភ្នែននៅមុនគេ ជាទេវរូបធំជាងគេក្នុងចំណោមទេវរូបដែលតម្កល់នៅជាមួយនោះ ។
- អង្គុយនៅលើជើងទម្រ៤ជ្រុងស្មើ ។

ព្រះគណេសទ្រង់គ្រឿងមាន ២ អង្គ :



ព្រះគណេសទ្រង់គ្រឿងទាំង ២ នេះ មានលក្ខណៈរូបរាងទំហំប៉ុនគ្នាគង់នៅលើបល្ល័ង្គដូចគ្នា មានការតុបតែងលំអក្បាលមានពាក់មកុដ និងលើខ្លួនមានពាក់គ្រឿងអលង្ការជាច្រើន ។ រូបទាំង ២ ធ្វើអំពីស្ពាន់ដូចគ្នា គឺ ពិតជាសាងឡើងក្នុងពេលដំណាលគ្នាប្រហែលជាសម័យក្រោយអង្គរ ។

រូបទី ១ ដៃស្ដាំកាន់ស័ង្ខ ដៃឆ្វេងកាន់កងចក្រ ។ អាទិទេពរូប នេះត្រូវបានគេរៀបនៅខាងជួរព្រះឥសូរ គឺជាអាទិទេពខាងព្រះឥសូរ ។

រូបទី ២ ដៃស្ដាំកាន់កងចក្រ ដៃឆ្វេងកាន់ស័ង្ខ ។ អាទិទេពរូបនេះត្រូវបានគេរៀបនៅខាងជួរព្រះនារាយណ៍ គឺជាអាទិទេពខាងព្រះនារាយណ៍ ។

### ៣_ ការគោរព

ក្នុងជំនឿផ្នត់គំនិតប្រជាជនខ្មែរ ព្រះគណេស គឺជាអាទិទេពខាងការពារឧបសគ្គ បញ្ចៀសឧបសគ្គឧបទ្រពចង្រៃទាំងឡាយកុំអោយមកបៀតបៀនដល់ខ្លួនប្រាណ ។ ពេលណាគេមានទុក្ខទោស គេតែងតែរំលឹកដល់អាទិទេពទាំងពីររូបនេះអោយជួយសង្គ្រោះជីវិតគេអោយរួចផុតពីគ្រោះមហន្តរាយ ។

ពេលមានសង្គ្រាមម្ដងៗគេតែងបន់ស្រន់ព្រះគណេសអោយជួយគេ ។ ជួនកាលគេឆ្លាក់រូបនេះរក្សាភ្ជាប់ខ្លួនគេដើម្បីអោយជួយការពារ ។ ដោយសារឥទ្ធិពលនៃព្រះគណេសនេះហើយ បានជាក្នុងសម័យព្រះបាទជ័យវរ្ម័នទី ៧ ប្រជាជននាំគ្នាគោរពអាទិទេពរូបនេះគ្រប់ៗគ្នា ។

ជារួម ពេលសព្វថ្ងៃនេះពិតមែនតែឥទ្ធិពលនៃព្រះគណេសត្រូវបានធ្លាក់ចុះក៏ដោយ ក៏ផ្នត់គំនិតប្រជាជនខ្មែរជំនាន់មុនៗដែលបានសេសសល់ជីវិតដល់សព្វថ្ងៃនេះមានជំនឿ និងបានចូលរួមចំណែកកសាងសន្តិភាព កសាងមាតុភូមិ និងអត្តសញ្ញាណជាតិខ្មែរបានគង់វង្សរហូតដល់សព្វថ្ងៃនេះ ។

**អនុបណ្ឌិត គួយ សូគាន**

**សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ**

ដកស្រង់រូបភាពពីឯកសារសារណាថ្នាក់បរិញ្ញាប័ត្រ (ស្លាបព្យកម្មខ្មែរនៅក្នុងជំនឿព្រហ្មញ្ញសាសនា ដឹកនាំដោយលោក គួយ សូគាន) ទំព័រ ៧០

# ទំនៀមទំលាប់ និងប្រពៃណីខ្មែរ ស្ដីពីការអប់រំចរិយាសម្បត្តិ

## ១. តែងខ្លួន

ក្នុងសង្គមនីមួយៗ មនុស្សចាំបាច់ត្រូវស្គាល់ពេលវេលា កាលៈទេសៈ និងបរិយាកាសដែលយើងរស់នៅមានតាំងពីការទទួលទាន ដេក ដើរ ឈរ អង្គុយ ដោយប្រកាន់ចរិយា និងឥរិយាបថថ្លៃថ្នូរ ទើបសមជាពលរដ្ឋរស់នៅក្នុងប្រទេសដែលមានការរីកចំរើនពិតប្រាកដ។ ដើម្បីធ្វើខ្លួនអោយបានសមរម្យ យើងត្រូវរៀបចំតាំងពីការតាក់តែងខ្លួនឡើងទៅ ។ ទោះបីយើងស្ថិតក្នុងជីវភាពក៏រិតណាក៏ដោយ ក៏ការរៀបចំខ្លួនរបស់បុគ្គលម្នាក់ៗ ជារឿងផ្សេងមួយដែលមិនទាក់ទងទៅនឹងជីវភាពទាំងស្រុងនោះទេ។ ហេតុអ្វីបានជាថា ដូច្នោះ ? ពីព្រោះក្នុងការរស់នៅ មនុស្សទោះជាលំបាកយ៉ាងណាក៏ដោយ ក៏គង់ជៀសមិនផុតពីការទិញដូរសំលៀកបំពាក់ ឬចំណាយផ្សេងៗដែរ បើយើងចំណាយហើយ តើហេតុអ្វីក៏មិនធ្វើអោយបានសមរម្យ ?

យើងសូមជំរាបថា ការរៀបចំតាក់តែងខ្លួនក៏ជាកិច្ចមួយដ៏សំខាន់ក្នុងចំណោមកិច្ចដ៏ច្រើនទៀតដែលយើងរាល់គ្នាមិនថាបុរស ឬស្ត្រីឡើយ ត្រូវរិះគិតអោយម៉ត់ចត់ព្រោះការតែងខ្លួននេះ បើមិនស្លៀកពាក់អោយសមរម្យ ត្រឹមត្រូវទៅតាមលក្ខណៈនៃពិធីបុណ្យ ឬពិធីណាមួយដែលគេចាត់ចែងនោះទេ យើងនឹងត្រូវទទួលសេចក្ដីរិះគន់ ចំអកឡកឡឺយអំពីអ្នកដទៃមិនខាន ។

យើងគប្បីព្យាយាមគយគន់អ្នកទាំងពួងតែងខ្លួនដែលសមរម្យតាមចាស់ តាមក្មេង កុំគប្បីទៅចំណាំពេញចិត្តនឹងពណ៌សំពត់ ពណ៌ព្រៃ ។ ការរៀបចំខ្លួនក្មេង និងចាស់ពុំដូចគ្នាទេ បើចាស់ទៅតែងខ្លួនដូចក្មេងក៏ពុំសម ក្មេងតែងខ្លួនដូចចាស់ក៏ពុំសមដែរ ។ ឯដំណើរអ្នកមាន ឬអ្នកក្រខ្សត់ អ្នកធំ ឬអ្នកតូច ឥតមានជំទាស់ថាអ្វីឡើយ ស្រេចតែនឹងមានទ្រព្យធ្វើបានត្រឹមណាយកត្រឹមនោះជាខ្នាតទៅចុះ កុំអោយតែធ្វើហួសប្រមាណខ្លួន ។

គ្រឿងប្រដាប់សំរាប់តែងខ្លួន លោកញែកជា ៣ ជំពូកអោយដាច់ពីគ្នា គឺ សំលៀកបំពាក់ គ្រឿងអលង្ការ និងគ្រឿងក្រអូប។ គ្រឿងប្រដាប់ដែលមាននៅក្នុងជំពូកទាំង ៣ នេះ មិនមែនប្រើទៅសមរម្យបានគ្រប់គ្នាទេ ។

## ២. សំលៀកបំពាក់

យើងកុំគប្បីសំគាល់ ឬអោយតំលៃទៅលើសំពត់ដែលមានតំលៃថ្លៃថាប្រសើរនោះ ហើយយកជាប្រមាណនោះឡើយ ព្រោះព្រៃក្តី សំពត់អំបោះក្តី ។ល។ រមែងមានពណ៌ផ្សេងៗគ្នា ដូចនេះយើងត្រូវរើសយកពណ៌ណាដែលសមល្មមនឹងសម្បុរស្បែកយើង ពណ៌ណាសមនឹងចំណាស់យើង ទោះបីមានផ្កា ឬលាតក៏កុំអោយមានទំនាស់ពុំសមរម្យនឹងរូបឆោមលោមពណ៌របស់យើង ។ សំលៀកបំពាក់នេះ ត្រូវចែកទៅទៀតតាមទំលាប់ទំនៀមផង តាមសម័យនិយមផង តាមផ្លូវការ និងតាមរដូវផង ។ តើយើងគប្បីស្លៀកពាក់អោយត្រូវតាមទំនៀមទំលាប់ និងសម័យនិយមនៅពេលណាខ្លះ ?

១. ទៅវត្ត (ក្នុងឱកាសបុណ្យក្តី ឥតបុណ្យក្តី) ។

២. ទៅបុណ្យខ្មោច : សពនៅលើផ្ទះ ហែសព ឈាបនកិច្ច បញ្ចុះសព ។

៣. ទៅចូលរួមពិធីមង្គលការ ។

៤. ទៅធ្វើការងារផ្សេងៗ ។

៥. ទៅដើរកំសាន្ត ។

៦. ទៅលេងផ្ទះបងប្អូន មិត្តសំលាញ់ ។

៧. នៅផ្ទះ ។

ការកាន់ទំលាប់ទំនៀមជាការប្រសើរណាស់ក៏ពិតមែនហើយ ប៉ុន្តែទំលាប់ឯណាដែលប្រែប្រួលទៅតាមសម័យនិយមហើយ ទំលាប់នោះមិនអាចនៅជាទំនៀមតទៅទៀតឡើយ ។

រឿងសំលៀកបំពាក់នេះ ផ្លាស់ប្តូរច្រើនបែបណាស់ ។ តែសំរាប់ចូលគាល់ព្រះរាជាក្តី មង្គលការក្តី ការកាន់ទុក្ខក្តី ពុំអាចផ្លាស់ចោលទំនៀមទំលាប់ចាស់បុរាណដាច់ស្រឡះបានទេ ។

ក. ទៅវត្ត

ស្ត្រីនិងបុរសមានរបៀបរៀបចំខ្លួនប្រាណទៅវត្តប្រកបដោយដំណើរសង្រួមតាំងពីឫកពារ ព្រមទាំងសំលៀកបំពាក់ទៀតផង អោយល្មមសមរម្យ កុំប្រើពណ៌ឆើតឆាយពេក ។ សំលៀកបំពាក់ទៅវត្តក៏គប្បីបិទបាំងរូបកាយអោយបានគត់មត់ល្អ ។ សំរាប់ស្ត្រីត្រូវប្រុងប្រយ័ត្នកុំអោយស្លៀកពាក់ខើចខ្លីពេក ឬចំហមុខក្រោយ អោយលេចឃើញទីដែលបង្កើតឡើងនូវតម្រេកដល់បុរស។ យើងដឹងហើយថា ព្រះសង្ឃជាអ្នកវៀរចាកកាមរាគ ព្រះអង្គតែងលះបង់សម្បត្តិគ្រហស្ថក្នុងលោកិយនេះ ប្រាថ្នាបោសរូបកិលេសអោយបានស្រាលស្តើង។ លោកតាំងអារាម អាស្រមដោយឡែក ដើម្បីរក្សាភាពស្ងប់ស្ងាត់ ដើម្បីធ្វើសីលអោយបរិសុទ្ធ ដើម្បីសេចក្តីសុខក្នុងលោកនេះ និងលោកឯមុខ ។ ចុះបើស្ត្រីជាអ្នកធ្វើឫកពារ ជាដំណើរមិនគួរគប្បីនៅមុខព្រះសង្ឃ ព្រោះព្រះសង្ឃនៅជាបថុជ្ជនដែរក៏គង់តែមានដួងហឫទ័យវិបល្លាស ប្រែប្រួលខ្លះមិនលែង។ ដូចនេះ ស្ត្រីចូលវត្តគប្បីប្រើកាយវិការ ឫកពារនិងសំដីអោយសមរម្យកុំអោយស្និទ្ធស្នាលនឹងព្រះសង្ឃពេក។

បុរសគេធ្លាប់ស្លៀកសំពត់ចងក្បិន ខោចិន ពាក់អាវកុត ឬអាវចិនប៉ុណ្ណោះ ល្មមហើយយើងមិនចាំបាច់គ្រវាត់ក្រមាពីលើអាវទៀតទេ ។ តែបើរៀបចំខ្លួនតាមទំនើបថ្មីក៏បានកុំតែពាក់ស្បែកជើងឡើងកុដិលោក ឡើងព្រះវិហារឬព្រះចេតិយ ។

ស្ត្រីធ្លាប់ស្លៀកសំពត់ចងក្បិន សំពត់សំឡុយ ឬខៀន ពាក់អាវបំពង់ខ្លី ឬអាវបំពង់វែង តែគេតែងមានក្រមាដណ្តប់បិទទ្រូងទៀត នេះជាការចាំបាច់ ។ ដល់មកសតវត្សនេះ អរិយធម៌ផ្សេងៗចូលមក សំលៀកបំពាក់បណ្តាជនផងទាំងពួងក៏រីកចំរើនទៅតាមបែបផែននោះដែរ ព្រមទាំងការរចនាផ្សេងៗទៀតក៏ ល្អលើសលុបជាងពីសម័យបុរាណច្រើនបែបច្រើនយ៉ាងណាស់ ហើយប្លែកៗគ្នាផង ។ ត្រង់នេះ ស្ត្រីត្រូវចាំកុំភ្លេចថា ការប្រើសំពត់អាវទៅវត្តកុំគប្បីប្រើពណ៌ឆើតឆាយអាវវៀលក គ្មានដៃ ហើយឥតពានាក្រមា ឬកន្សែងនោះ ។

(នៅមានត)

លោកស្រី ឈឹម ចន្ទសារា អធិការបឋមសិក្សា

ដកស្រង់ពី "ទំនៀមទំលាប់ និងប្រពៃណីខ្មែរ" របស់ឧកញ៉ាមហាមន្ត្រី ញ៉ុក ថែម ឆ្នាំ ១៩៥៨

# អំពីចំណេះ

មនុស្សរស់នៅនាពេលបច្ចុប្បន្នក្តោបក្នុងអតីតកាលនិងអនាគតកាល ហើយបើតាមទស្សនៈសាសនាគឺមានជាតិមុន ជាតិនេះ និងជាតិក្រោយ ហើយកាលទាំង ៣ នេះមានចំណងទាក់ទងគ្នា ។ ដូចនេះ មនុស្សត្រូវតែផ្សារភ្ជាប់កាលនីមួយៗដោយត្រូវធ្វើយ៉ាងណាអោយខ្លួនអនុវត្តអោយខាងតែបានទូវលក្ខខណ្ឌដែលទស្សនវិជ្ជាបានលើកឡើងថាតើ ÷

- អាចដឹងអ្វីខ្លះពាក់ព័ន្ធពីអតីតកាល?
- ត្រូវធ្វើអ្វីនាពេលបច្ចុប្បន្នកាល?
- សង្ឃឹមអនាគតយ៉ាងណា ? ។

## ក. ពាក់ព័ន្ធពីអតីតកាល

ចំណេះ មានន័យថា សេចក្តីចេះ ដំណើរដែលចេះ( វចនានុក្រម ជួន ណាត ទំព័រ ១៣១) ហើយន័យលំអិតត្រូវមើលពាក្យ "វិជ្ជា" ( ទំព័រ ៧៣២) គឺសេចក្តីដឹងច្បាស់ ការចេះដឹង វេទមន្ត មន្តអាគម : "វិជ្ជាជាទ្រព្យ បើបានគ្រប់សព្វលើសទ្រព្យនានា អ្នកមានទ្រព្យស្រាប់ អាប់ឥតវិជ្ជា មិត្តភក្តិផងគ្នា គេច្រើនមើលងាយ ។ល។" ។

ខ្មែរយើងច្រើនប្រើគួប : ចំណេះ + ដឹង > ចំណេះដឹង ទន្ទឹមនឹងនេះ តាមទស្សនៈលោកកេង វ៉ាន់សាក់ ក៏មាននិន្នាការចង់ប្រើពាក្យត្រលាស់ ដោយកាត់ព្យាង្គចុងក្រោយចេញ : ចំណឹងដេះ > ចំណឹង ។

ឈរលើទស្សនាទាននៃបញ្ញត្តិទស្សនវិជ្ជា អ្វីៗមានបដិបក្ខ ឧទាហរណ៍ : ស ≠ ខ្មៅ, ល្អ ≠ អាក្រក់... ។ "ចំណេះ" ក៏ត្រូវចូលក្នុងផ្លូងនេះដែរ ។ ដូចនេះ "ចំណេះដឹង" ≠ ចំណេះមិនទាន់ដឹង ពោលគឺចំណេះពិតរកឃើញហើយ (connaissance acquise) និងចំណេះស្ថិតនៅជាអាថ៌កំបាំងដែលតំណក្រោយៗត្រូវបន្តវែនស្រាវជ្រាវ (connaissance à acquérir) ។

ក្នុងករណីនេះ យើងសូមលើក "ចំណេះដែលរកឃើញហើយ" ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌទី ១ ដោយផ្អែកលើបញ្ជីបណ្ណាល័យ និងមជ្ឈមណ្ឌលឯកសារនានា។ នេះយើងមិនបានរាប់ទស្សនាវដ្តី ផែនទី ស៊ីឌីរ៉ូម សំនុំឯកសារអំពីសន្និសីទ សំនុំឯកសារស្រាវជ្រាវ របាយការណ៍ កុន វីដេអូ រូបភាព ហ្វីល ស្លាយ រូបថត និក្ខេបបទ មីក្រូហ្វីល ឌីវីឌី បណ្ណសារ...។

គួរកត់សំគាល់ថា នៅលើលោកនេះ មានបណ្ណាល័យមួយចំនួនមានសៀវភៅយ៉ាងច្រើនអនេកប្បការ ។

ប្រជាជនកម្ពុជាបានប្រគល់សញ្ញាប័ត្របណ្ឌិតកិត្តិយស (Docteur honoris causa) ថ្វាយសម្តេចជួន ណាត ដោយកោតសរសើរមិនដាច់ពីមាត់ថា ព្រះអង្គបានសិក្សាចប់គម្ពីរព្រះត្រៃបិដកដែលមាន៨ម៉ឺន៤ពាន់ធម្មក្ខន្ធ ហើយប្រមូលចងក្រងវចនានុក្រមខ្មែរក្នុងនាមព្រះអង្គជាអគ្គលេខាធិការនៃគណៈកម្មការតាក់តែងវចនានុក្រម និងអត្ថបទសៀវភៅជាច្រើន ហើយបានចាត់ថា ក្នុងមួយព្រះជន្មាយុរបស់ព្រះអង្គ ពេលវេលាសឹងហាក់ដូចតិចតួចឥតឧបមា ។

លើគំនរបេតិកភ័ណ្ឌវិញ្ញាណមហិមានេះ គ្មានជនណាម្នាក់អាចស្វែងយល់ដឹងបានសព្វគ្រប់ឡើយបណ្ដាលអោយសាកលវិទ្យាល័យលើលោកកសាងមហាវិទ្យាល័យជាច្រើន ក៏ដូចជាគ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈមានឯកទេសផ្សេងដើម្បីឆ្លើយតបនឹងឧបនិស្ស័យនិស្សិតអោយបានទាន់ពេលវេលា ។

ក្នុងករណីនេះ នៅពេលវិទ្យាសាស្ត្ររីកចំរើនលោតផ្លោះ លោកសាកលីសាផ្លាំង (Charlie Chaplin) មានការព្រួយបារម្ភជាខ្លាំង អំពីការបាត់បង់ការងារធ្វើ ព្រោះបើបុគ្គលចេះតែនេះ ហើយមិនចេះនោះ នៅពេលអស់ការងារនេះ គេមិនអាចធ្វើការងារនោះបានទេ ។ ប្រការនេះ ត្រូវតែផ្ដល់មុខវិជ្ជាអោយបានទូលាយសមស្របតាមតំរូវការទីផ្សារ ។

ចំពោះឯកទេសកម្មនេះទៀតសោត ក៏មានបដិបក្ខកម្មគ្នាខ្លះៗដែរ រីក្នុងការស្រាវជ្រាវស្វែងយល់អំពីទ្រឹស្ដីដើមក៏មានការបែកផ្លូវគ្នាទៀតផង : ពុទ្ធសាសនាមហាយាន ពុទ្ធសាសនាហីនយាន គ្រិស្ដសាសនាមានច្រើននិកាយជាដើម បណ្ដាលអោយអង្គការយូណេស្កូធ្វើការណែនាំដល់ការអប់រំអោយឈរលើស្ដម្ភបួន ជាពិសេស "ចេះរួមរស់ជាមួយគ្នា" ។

ដូចនេះ ថ្វីបើពុទ្ធិលទ្ធកម្មមានស្រាប់ហើយក្ដី ក៏យើងមិនអាចធ្វើអោយសង្គមមានភាពសុខដុមរមនាបានដែរ ប្រសិនបើយើងមិនចេះផ្គុំអោយស៊ីសង្វាក់គ្នា ខ្មែរយើងតែងពោលថា "ទ្រដោយទ្រ, ស្ដរដោយស្ដរ..." យ៉ាងនេះ ។ គួរកត់សំគាល់ថា ខ្មែរយើងធ្លាក់ចូលក្នុងធ្លុងគ្រោះថ្នាក់ចាស់ៗដដែលៗ ដូចជាគេដឹងថាការបែកបាក់សាមគ្គីនាំអោយខ្សោយ "...ចង្កឹះមួយបាច់កាច់មិនបាក់ " ។

ការនិយមមិនអោយតំលៃលើមាតុភាសា( ភាសាកំណើត) លើតំលៃទស្សនាទានរបស់ជាតិ គឺជាប្រការមួយត្រូវបានគរុកោសល្យវិទូមិនអាចទទួលយកបាន ។ តែក៏យើងមិនត្រូវចង្អៀតចង្អល់នឹងប្រើភាសាបរទេសនេះទេ ។ បច្ចុប្បន្ននេះ ប្រទេសដែលមិនប្រើអក្សរឡាតាំង ក៏ត្រូវប្រើវាដែរ សំរាប់អក្សរកាត់ផ្នែកគណិតវិទ្យា គីមីវិទ្យា និងរូបមន្តសំខាន់ៗ ។ ប្រការនេះ អង្គុលីលេខក្ដី កុំព្យូទ័រក្ដី ត្រូវបញ្ចូលចរិកអក្សរឡាតាំង ឧទាហរណ៍ : រូបមន្តទឹកៈ $H_2O$ បារ៉តៈ Hg ប្រាក់ៈ Ag ហើយក៏តំរូវអោយសិស្សចេះចារិកអក្សរបន្ថែមទៀត ។

## ខ~ កិច្ចការរបស់បច្ចុប្បន្នកាល

នរណាក៏មានអតីតកាល ហើយម្នាក់ៗថ្វីបើខ្លួនរស់នៅស្រោចស្រពដោយអ្វីៗយ៉ាងទំនើបក៏ដោយ ក៏បច្ចុប្បន្នកាលរបស់គេមិនបានផ្ដាច់ចេញពីអតីតកាលបានឡើយ ។ឧទាហរណ៍ : ប្រជាជនកម្ពុជា ពិសេសយុវជនដែលកំពុងទទួលឥទ្ធិពលពីក្រៅក្ដី ក៏ពួកគេនៅតែកោតសរសើរ និងមានមោទនភាពចំពោះបេតិកភណ្ឌសង្គម-ធម្មជាតិរបស់គេជានិច្ច ។ យើងមានជំនឿថា យុវជនជាតិណាក៏ដូចជាតិណាដែរនៅពេលត្រូវគេបំពាក់អរិយធម៌ដទៃ ដោយអោយតំលៃអរិយធម៌គេកាន់តែប្រសើរកាន់តែខ្ពស់សាបព្រោះដើម្បីបំបាត់អរិយធម៌របស់ខ្លួន ពេលនោះយុវជននោះនឹងមានការភ្ញាក់រលឹកជាមិនខាន ។មនុស្សកាន់តែចាស់ កាន់តែខិតខំអួតអាងពីអត្តសញ្ញាណរបស់ខ្លួន មនុស្សនោះកាន់តែស្រលាញ់អតីតកាលរបស់ប្រទេសខ្លួន មនុស្សវ័យចាស់ខ្មែរចូលចិត្តចំរៀងបូរាណ ហើយតែងពោលថា "ទាំងអស់នេះទុកអោយ ឯងហើយ" ។

ទស្សនវិទូ អ្នកប្រាជ្ញទាំងឡាយលើលោក តាំងពីសូក្រាត, សមណគោត្តម, ខុងជឺ និងអ្នកប្រាជ្ញខាង វិទ្យាសាស្ត្រដូចជា Démocrite, Einstein, Descartes... ដែលគេសន្មតថា គ្មាននរណាប្រដៅឡើយនោះ ក៏លោកទាំង

នោះ មានអតីតកាលរបស់លោក និងបច្ចុប្បន្នកាលជាកំណត់ ។ ព្រះសមណគោត្តម មុនបានសំរេចពោធិញ្ញាណ ក៏ព្រះអង្គបានសិក្សាគម្ពីរត្រៃវេទសព្វគ្រប់តាមរយៈព្រឹទ្ធបុរសព្រាហ្មណ៍ ។

ដូចនេះ ព្រះពុទ្ធអង្គបានបំពេញភារកិច្ចអតីតកាលមួយដ៏ជ្រាលជ្រៅដែលនាំអោយព្រះអង្គសំរេចនូវចំណេះថ្មី ហើយបច្ចុប្បន្នកាលរបស់ព្រះអង្គបានបង្កើតសេចក្តីសង្ឃឹមមួយបែបប្រាកដនិយម ចតុរារិយសច្ចសំរាប់ដំណោះស្រាយជីវិតទាំងផ្លូវសំភារៈ ទាំងផ្លូវចិត្ត ។

ចំពោះមុខនេះ ពលរដ្ឋកម្ពុជាយើងមានចំណេះដឹងក្នុងការប្រើប្រាស់បច្ចេកទេសទំនើបមិនទាន់បានទូលំទូលាយនៅឡើយ។ តែយើងក៏កំពុងមានមោទនភាពខាងទ្រឹស្តីពីស្រុកទេស : អត្តសញ្ញាណជាតិ អរិយធម៌របស់ខ្លួន និងកំពុងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិ មាតុភូមិអោយមានការរីកចំរើនដូចបណ្តាប្រទេសជឿនលឿនលើសកលលោក។

( នៅមានត )

**កែវ យ៉ារ**

## កុំសេពថ្នាំញៀន

**កុំសេពថ្នាំញៀន**
អ្នកផងទំនៀន
ថាជនពាលា
ប្រព្រឹត្តផ្តេសផ្តាស
ក្មេងចាស់និន្ទា
រស់នៅចាត់ជា
ជនក្រៅសង្គម។

**កុំសេពថ្នាំញៀន**
សង្វាតខំរៀន
គោរពចាស់ទុំ
មើលឃើញបន្ទា
កុំយល់ថាព្រំ
កុំលើកថ្មភ្នំ
ទំលាក់លើជើង។

**កុំសេពថ្នាំញៀន**
ត្រូវចេះខ្មាសអៀន
ញាតិមិត្តនៃយើង
រក្សាកេរ្តិ៍ឈ្មោះ
កុំរស់ដូចឈើង
កុំកាន់ដុំភ្លើង
ស្រែកថាសប្បាយ។

**កុំសេពថ្នាំញៀន**
យ៉ាម៉ាអាភៀន
នាំអោយអន្តរាយ
ស្លាយពូជស្លាយពង្ស
ស្លាយរាងរូបកាយ
ត្រូវចៀសអោយឆ្ងាយ
កុំស្លាយថ្នាំញៀន។

**ផាត់ សាំ**



# ចិត្តវិទ្យា-អប់រំ

## ភាពធូរធេរនៃការធ្លាក់ចុះក្នុងការសិក្សារបស់កុមារ

ធម្មជាតិរបស់កុមារពោរពេញទៅដោយថាមពលដែលអាចអោយគេមានកំលាំងពលំ ឆ្ពោះទៅរកការរហ័សរហួន និងរពិសណាស់ ជាពិសេសគេរៀនឆាប់ចេះ លេងច្រើន ចង់ដឹង និងឆ្ងល់ច្រើន។ ចូរយើងស្រមៃទៅលើទារកដែលទើបចេះក្រឡាប់ ឬដើរ គេតែងយកអ្វីមួយដែលគេអាចយកបានមកបៀមនឹងមាត់ តែបើវត្ថុនោះមានបញ្ហា គេតែងបោះចោល ឬវារទៅរកអ្វីផ្សេងទៀត ហាក់ដូចជាមិនចេះនឿយហត់អញ្ជឹងដែរ។ ពេលដែលកុមារវិវត្ត ជានិច្ចកាលកុមារចង់ដឹង និងចង់បាននូវអ្វីដែលថ្មី រីងរូសច្រើន ពោរពេញទៅដោយថាមពល សេចក្តីរីករាយ និងរំភើប។ ជាការពិតណាស់ កុមាររីកលូតលាស់តាមធម្មជាតិ តាំងពីការរៀនវារ រៀននិយាយ ចង់ដឹង ចង់ឃើញនូវអ្វីដែលថ្មី ចង់ច្រៀងរាំ គូរគំនូរ ឬទៅរៀននៅសាលាជាដើម។ កុមារតែងតែសួរដេញដោលអ្វី១សព្វបែបយ៉ាង ទៅលើអ្វីដែលគេឃើញ លឺ ប៉ះ។ ពួកគេពោរពេញទៅដោយការជឿជាក់ និងមានអានុភាព។ ពេលកុមារចំរើនវ័យវឌ្ឍនាការ ការជឿជាក់របស់គេ និងការចាប់អារម្មណ៍ក្នុងការសិក្សា កាន់តែស្រុតចុះទៅ១។ ឪពុកម្តាយ ឬអ្នកមានវ័យចំណាស់តែងតែគិតថា នេះជាលក្ខណៈរបស់កូនក្មេងចំពោះការបាត់បង់ជំនឿចិត្ត និងចំណាប់អារម្មណ៍ ពេលដែលគេធំឡើងដោយមិនបានស្វែងយល់ពីចិត្ត និងអាកប្បកិរិយារបស់គេឡើយ។ អ្នកចិត្តវិទ្យានាពេលបច្ចុប្បន្ននេះបានសិក្សាស្រាវជ្រាវ លាតត្រដាងថា កុមារដែលបាត់ជំនឿចិត្ត និងចំណាប់អារម្មណ៍របស់ខ្លួន គឺដោយសារតែកំហុសដ៏តូចតាចរបស់ឪពុកម្តាយ និងបងរបស់គេ រួមទាំងយើងទាំងអស់គ្នាផង។ បរិស្ថាន បរិយាកាសសង្គម និងអាហារូបត្ថម្ភ ក៏ជាកត្តាលីករដ៏សំខាន់ណាស់ដែរ។ មែនហើយ កុមារចូលចិត្តសួរដេញដោលពីនេះ ពីនោះ ឥតឈប់ឈរ ដែលធ្វើអោយមនុស្សដែលចាស់ជាងពួកគេឆ្លើយរហូតដល់ធុញ ហើយជួនកាលតំហក ឬដេរក៏សឹងមាន។ ជួនពេលខ្លះយើងមានអារម្មណ៍មិនល្អ ហើយមានកុមារណាម្នាក់ធ្វើអោយរបស់មានតំលៃបាក់បែក ឬបាត់ដោយចៃដន្យ រឺសួរសំណួរមិនគួរសួរ ពោលពាក្យមិនសមរម្យ ប្រលែងលេងច្រើន ឡូឡា រឺមិនស្តាប់បង្គាប់ ពេលនោះយើងជេរប្រមាទ បន្ទុះបង្អាប់ ពោលពាក្យមិនសមគួរ ជាដើម រហូតដល់អ្នកខ្លះទៀតទះតប់វាយនឹងរំពាត់ ឬដាក់ទណ្ឌកម្មផ្សេង១ទៀតទៅលើគេ។ ការនេះកើតឡើងម្តងជាពីរដង

មិនថ្វីទេ តែបើកើតម្ដងហើយម្ដងទៀតជារៀងរាល់ពេលនោះ កុមារពិតជាជឿថា ខ្លួនគេពិតជាភ្លើល្ងង់ដូច្នោះមែន ភ័យខ្លាច បាត់បង់ជំនឿចិត្ត និងអារម្មណ៍ក្នុងការរៀនសូត្របន្តិចម្ដងៗ។ នេះជាកំហុសដ៏តូចមួយរបស់មនុស្សដែលមានអាយុច្រើនជាងគេ ហើយកំហុសដ៏តិចតួចនេះធ្វើអោយកុមារបាត់បង់សេចក្ដីក្លាហាន លែងហ៊ានសួរនាំសាក ពិសោធ ល្បងបញ្ចេញមតិ ប៉ាន់ប្រមាណឆ្លើយសំណួរ ឬអ្វីទៀតជាច្រើនដោយសារការខ្វះជំនឿចិត្តរបស់គេ។ ដូច្នេះ យើងត្រូវឈប់ប្រើអំពើមិនគប្បី បើទោះបីជាយើងជាឪពុកម្ដាយ ជាបង ជាគ្រូ ឬជាអ្វីក៏ដោយ យើងត្រូវផ្ដល់ដំបូន្មានល្អៗ បង្ហាញផ្លូវពន្យល់ណែនាំ ផ្ដល់ឧទាហរណ៍ជាប្រចាំនោះ គេនឹងចាប់ផ្ដើមយល់ និងឈប់ប្រព្រឹត្តរឿងមិនល្អ ហើយយើងត្រូវដឹងថាគ្មាននរណាម្នាក់សុក្រឹតនោះឡើយ កុមារក៏ដូច្នោះដែរ។

ម្យ៉ាងទៀត ពេលដែលកុមារមិនទទួលស្វាគមន៏ពីមជ្ឈដ្ឋាន គ្រួសារ គេមានគំនិតទៅរកបរិស្ថានខាងក្រៅដែលនាំអោយកុមារកាន់តែឃ្លាតពីសង្គមមួយដែលនិយមការសិក្សា។ ដូច្នេះ យើងជារៀមច្បងគួរណាស់តែរៀបចំអាកប្បកិរិយាត្រឹមត្រូវ និងកែតំរូវអត្តចរិកមិនត្រឹមត្រូវ ដែលជាកំហុសមួយធ្វើអោយកុមារបាក់ទឹកចិត្តនឹងការរៀនសូត្រ។

ដោយលោក : អ្នួន ស៊ីឡុត
សាស្ត្រាចារ្យឯកទេសភាសាអង់គ្លេស
វិទ្យាល័យហ៊ុន សែន បល្លង្កកំពង់ធំ

## គ្រូចនាំគ្នាការពារព្រលឹងខ្មែរ

(ពាក្យ៧)

ព្រលឹងជាតិខ្មែរកេរដូនតា ត្រូវថែរក្សា ការអោយគង់
ជាតិបាត់ព្រលឹង នឹងលិចលង់ រលាយពូជពង្ស បាត់ឈ្មោះខ្មែរ ។
ព្រលឹងជាតិខ្មែរ វិសេស គាប់ ទំនៀមទំលាប់ ច្បាប់ហូរហែ
អក្សរសិល្បៈ ចំលាក់ដែរ សំខាន់មនុស្សខ្មែរ ទាំងប្រុសស្រី ។
អក្សរសាស្ត្រខ្មែរ មានច្រើនវគ្គ វណ្ណយុត្តិព្យញ្ជនៈ ស្រៈវែងខ្លី
សិល្បៈរបាំ តូរ្យតន្ត្រី ក៏មានឈ្មោះល្បី លើសកល ។
បុរាណប្រាសាទ ស្អាតប្រណីត ក្បូរក្បាច់វិចិត្រ ឥតមានដល់
ប្រាសាទអង្គរ ល្អពេកសល់ ទៅដល់យល់ដឹង ព្រលឹងខ្មែរ ។
មនុស្សខ្មែរគឺជាព្រលឹងធំ អ្នកសាងសង្គម ខ្លាំងពូកែ
បើយើងបណ្ដោយ អោយមនុស្សខ្មែរ បាត់បង់គង់តែ ខ្មែរឈ្មោះផ្សេង ។

ដោយ : ឆាត់ សាំ

# ក្មេងមានះម្នាក់ (ការអប់រំពីសម័យសង្គមនិយម ១៨)

កាលណាមានពេលវេលាល្អ សិស្សក្នុងអន្តេវាសិកដ្ឋាននៃអនុវិទ្យាល័យ ចេញដើរកំសាន្តនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃអាទិត្យ ។ គេបានដឹកនាំពួកយើងខ្ញុំទៅលេងនៅទីរមណីយដ្ឋានប្រាសាទបុរាណនៅលើកំពូលភ្នំ រឺទីសំណាក់ធមិរបស់ព្រះសង្ឃ និងចាស់ទុំ ។

ថ្ងៃមួយនៃខែឧសភា គ្រូប្រចាំសប្តាហ៍បាននាំយើងខ្ញុំទៅលេងអារាមដ៏ស្ងាត់ជ្រងំមួយដែលមានដើមឈើធំៗជាច្រើន ។ ក្រោយពីចូលទៅក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ឋានៈ និងសង្កេតអារាមរួចហើយ លោកគ្រូនាំយើងទៅលេងក្នុងវាលមួយ ។ លោកបានផ្តែផ្តាំថា : "កុំឡើងដើមឈើទី១ កុំស្រែកឡូឡាទី២ ក្រៅពីនេះលេងអ្វីក៏លេងចុះ!" ហើយគាត់ទៅពិភាក្សាជាមួយព្រះសង្ឃពីរឿងធមិអារ្យនៅក្នុងវត្តនោះទៅ ។

ដើមគគីរអមសងខាងផ្លូវមានកំពស់លៃ្វធំៗ ។ ខ្ញុំបានក្រឡេកឃើញសត្វពពេចលេចក្បាលចេញពីមាត់រូងនៃដើមគគីរមួយដើមក្នុងកំពស់ប្រហែលដប់ប្រាំហត្ថ វាប្រហែលជាកំពុងក្រាបពងហើយមើលទៅ ។ ទិដ្ឋភាពនោះធ្វើអោយខ្ញុំត្រេកត្រអាល និងបង្ខំចិត្តខ្លួនឯងអោយចង់បានពងនោះ ។ តើខ្ញុំអាចប្រថុយកើតទេ ? បើច្បាប់ដាក់មកអោយខ្ញុំមិនអោយឡើងដើមឈើ ហើយលោកគ្រូនៅជិតៗនេះដែរ ដើមឈើក៏ធំហើយខ្ពស់ទៀត! ។ គំនិតមានះក៏កើតមានឡើងភ្លាម ការប្រមាថ ទាមទារអោយខ្ញុំប្រថុយដើម្បីសំដែងថ្វីដៃ ខ្ញុំត្រូវប្រតោងឡើងដើមគគីរដូចសត្វឆ្មា ។ ពេលនោះខ្ញុំមានចិត្តអល់អែក តែខ្ញុំសំរេចចិត្តថា ត្រូវតែឡើងអោយដល់ទាល់តែបាន ។ ខ្ញុំដោះអាវរបស់ខ្ញុំចេញចាប់ផ្តើមឡើងទៅអោយដល់ទិសដៅ ។ ផ្នែកខាងក្រោមនៃដើមគគីរគ្មានមែកទេ តែចំណែកពីរភាគបីខាងលើទើបមានមែកសាខា ហើយត្រង់ចំណុចចាប់ផ្តើមមានមែក មានរូងសត្វពពេចមួយ ។ មិត្តភក្តិរបស់ខ្ញុំផ្ទុំគ្នានៅខាងក្រោមទះដៃជំរុញខ្ញុំអោយខំឡើងទៅទៀត ឯពួកគេមើលមកខ្ញុំផង និងលួចមើលផ្លូវលោកគ្រូផង ក្រែងគាត់ចេញមកវិញ។ ខ្ញុំចង់បានស៊ុតសត្វពពេចជាខ្លាំង តែខ្ញុំក៏ភ័យព្រួយដល់ទណ្ឌកម្មរបស់លោកគ្រូយ៉ាងខ្លាំងផងដែរ ។ ខ្ញុំឡើងដល់រូងសំបុកសត្វ ហើយពពេចក៏ហើរចេញទៅ ខ្ញុំប្រមូលស៊ុតដាក់ក្នុងហោប៉ៅខោ ក៏ចាប់ផ្តើមចុះវិញ ។ រំពេចនោះ ខ្ញុំក៏រអិលខ្លួនចុះក្រោមជើងខ្ញុំទាំងសងខាងលែងទប់អ្វីជាប់ទៀតហើយ ការច្រកតាវគាបទំហំដើមឈើក៏ធ្វើពុំកើត ដោយសារឈើភ្លៅពេក ដៃខ្ញុំបានត្រឹមតែអោបដើមឈើ ហើយក៏ធ្លាក់រូដល់ដី សំលេងស្រែកយ៉ៃលាន់លឺឡើង ។ កំភួនដៃ ទ្រូង ភ្លៅរបស់ខ្ញុំត្រូវបានរលាត់ដាច់សាច់ចេញឈាម ពេលចុះមកដល់ដីវិញ ។ ខ្ញុំខឹងពេកក៏បំផ្លាញស៊ុតនោះចោលអស់ទៅ ព្រោះតែវានេះហើយដែលធ្វើអោយខ្ញុំពិបាក ។ ខ្ញុំឃើញលោកគ្រូធ្វើមុខមាំដាក់ខ្ញុំ ខ្ញុំគេចមុខចេញដោយខ្មាស់អៀនបំផុត ។ លោកគ្រូដើរមករកខ្ញុំ ហើយនិយាយថា : "ឯងនេះសមនឹងរំពាត់ខ្លាំងណាស់ ឥឡូវត្រឡប់ទៅវិញ" ។

យើងទាំងអស់គ្នាបានត្រឡប់មកដល់អនុវិទ្យាល័យវិញហើយ ។ លោកគ្រូប្រចាំសប្តាហ៍បានហៅខ្ញុំអោយចូលទៅការិយាល័យរបស់គាត់ ហើយបញ្ជាខ្ញុំអោយលុតជង្គង់ ។ ខ្លួនខ្ញុំចេញកំដៅភាយៗ ខ្ញុំក៏លុតជង្គង់នៅចំពោះមុខគាត់

ដោយអោបដៃទាំងពីរ និងបញ្ចេញវាចាសុំអង្វរករការលើកលែងទោសពីគាត់ដោយអាណិតអាសូរ ។ លោកគ្រូធ្វើជាគមិននិយាយមករកខ្ញុំមួយម៉ាត់សោះ ។ ខ្ញុំក៏តាំងចិត្តក្រោកឈរឡើងមានកំហឹងពុះកញ្ជ្រោល ស្ទុះទៅធាក់ជើងរបស់គាត់តាមទំងន់ជើងរបស់ខ្ញុំ ។ លោកគ្រូស្រែកសន្ធាប់ ហើយក៏រត់ក្តុងក្តាំងទៅបិទទ្វារយ៉ាងមាំរួចក៏ត្រលប់មករកខ្ញុំវិញ ។ ខ្ញុំដកខ្លួនទៅបាំងនឹងតុរបស់គាត់ខំស្រែកថា : "ក្លាហានឡើងក្មេងមានពូជសាសន៍ដូចគ្នា" ពេលនេះលោកគ្រូស្រាប់តែអស់សំណើចនូវពាក្យដែលខ្ញុំស្រែក ទើបគាត់និយាយថា : "យើងឈប់ខឹងនឹងគ្នាទៅ!" ។ ខ្ញុំនិងលោកគ្រូបានស្រុះស្រួលចិត្តគ្នា លែងខឹងគ្នាតទៅទៀតហើយ ។ ពេលវេលាបានធូរស្រាល ខ្ញុំក៏ចេញទៅរាយការណ៍ជូនលោកនាយកសាលាផងដែរ តែលោកពុំដេញដោលសួរអំពីហេតុផល បែរជាលើកលែងទោសអោយខ្ញុំទៀត ។

ចាប់ពីពេលនោះមក ខ្ញុំលែងប្រព្រឹត្តអំពើខុសឆ្គងនឹងច្បាប់របស់សាលា និងផ្សងព្រេងអាក្រក់ទៀតហើយ ។

**លោក ឌិ សាម៉ាន់ គ្រូបង្រៀនចូលនិវត្តន៍**

**ប្រែសំរួលពីអត្ថបទរបស់លោក Chateaubriand**

# មានះ

**មានះ មានបីយ៉ាង គឺ**

១. ប្រកាន់មាំសិប់ថា មានតែអញឯងជាអ្នកប្រសើរជាងគេ ក៏មើលងាយគេ ឥតជឿស្តាប់គោរពអ្នកណា ។

២. ប្រកាន់មាំសិប់ថា គេនិងអញស្មើៗតែគ្នា គេម៉េចអញម៉េច ប្រហែលតែគ្នា ក៏ឥតមានការសេពគប់រាប់រកយកគេជាគ្នា ។

៣. ប្រកាន់មាំសិប់ថា អញឯងជាអ្នកទន់ខ្សោយ ថយថោកជាងគេ គេដោយគេ អញដោយអញ ក៏ឥតមានការប្រាស្រ័យនឹងគ្នា ។

...មានះទាំងនេះ ជាប្រភពឬជាមូលដ្ឋាននៃសាមគ្គីភេទ[១] ។

វចនានុក្រមខ្មែរសម្តេច ជួន ណាត

(១)ការបែកបាក់សាមគ្គី ។




## តួលេខពត៌មានទូរគមនាគមន៍

❖ ចំនួនអ្នកប្រើប្រាស់អ៊ិនធើណិតនៅលើផែនដី :

- ឆ្នាំ ១៩៩៣ មាន ១០លាន
- ឆ្នាំ ២០០២ មាន ៥៨០លាន
- ឆ្នាំ ២០០៣ មាន ៦៦៥លាន

❖ ចំនួនអ្នកប្រើប្រាស់អ៊ិនធើណិតនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ :

- ឆ្នាំ ២០០១ មាន ១,៨លាន

❖ ចំនួនកុំព្យូទ័រនៅលើផែនដី :

- ឆ្នាំ ១៩៩៣ មាន ១៧៥លាន
- ឆ្នាំ ២០០២ មាន ៦១៥លាន
- ឆ្នាំ ២០០៣ មាន ៦៥០លាន

❖ ចំនួនកុំព្យូទ័រនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ :

- ឆ្នាំ ២០០១ មាន ១,៣លាន

❖ ចំនួនកុំព្យូទ័រមានភ្ជាប់បណ្តាញអ៊ិនធើណិតសំរាប់ប្រជាជន ១០០០នាក់ នៅឆ្នាំ២០០១ :

- ប្រទេស OCDE[១] ដែលមានចំណូលខ្ពស់ ៤០០
- ប្រទេសនៅអាមេរិកខាងត្បូង និងការ៉ាអ៊ីប ៤៩
- ប្រទេសនៅអឺរ៉ុបកណ្តាល និងខាងកើត ៤២,៨
- ប្រទេសនៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ៤១,៤
- ប្រទេស OCDE ៣៣២
- ប្រទេសដែលកំពុងអភិវឌ្ឍន៍ ២៦,៥
- រដ្ឋទាំងឡាយនៅភពអារ៉ាប់ ១៥,៦
- ប្រទេសនៅអាហ្វ្រិកខាងត្បូងសាហារ៉ា ៧,៨

**ប្រភព** : Le nouveau Courrier/ October 2003

(1) OCDE= Organisation de coopération et de développement économique ( អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច)

# ភាសាដែលប្រើប្រាស់ច្រើនជាងគេនៅលើពិភពលោក (គិតជាលាននាក់)




"មនុស្សទាំងឡាយដែលខ្ញុំបានជួប តែងមានចំណុចណាមួយប្រសើរជាងខ្ញុំៗ ដូច្នេះហើយ ទើបខ្ញុំអាចរៀនសូត្របានអំពីគេៗ"

*"Tout homme que je rencontre m'est supérieur en quelque sorte. C'est pourquoi je m'instruis auprès de lui."*

**Emerson (Ralph Waldo)**

**ទស្សនវិទូអាមេរិក (១៨០៣-១៨៨២)**

---

**ប្រភព :** Population data.net, 2000

* mandarin = ភាសាផ្លូវការរបស់ចិន, ភាសាចិនកុកងឺ




# គោលបំណងនៃការអប់រំសីលធម៌

គោលដៅអប់រំសីលធម៌បានគូសបង្ហាញនូវផែនការសកម្មភាពមួយសំរាប់ការអនុវត្តអោយកាន់តែប្រសើរឡើងទាំងក្នុងសាលារៀនក៏ដូចជាក្នុងជីវិតសង្គមប្រចាំថ្ងៃ ។

ការអប់រំសីលធម៌បានជួយដល់បុគ្គលម្នាក់ៗអោយបង្កើននូវបុគ្គលិកលក្ខណៈឯករាជ្យមួយដែលអាចមានលទ្ធភាពប្រែក្លាយសកម្មភាពរបស់គេទៅជាការទទួលខុសត្រូវ និងភាពច្នៃប្រឌិតដែលមានទំនាក់ទំនងទៅនឹងមិត្តភក្តិ ធម្មជាតិ សង្គមជាតិ អន្តរជាតិ ដើម្បីដឹកនាំខ្លួនគេឆ្ពោះទៅរកសន្តិភាព និងអភិវឌ្ឍន៍សង្គមជាតិ ។

## ១. មូលដ្ឋាននៃការអប់រំសីលធម៌

| | |
|---|---|
| ១-ឪពុកម្តាយ និងបរិស្ថានគ្រួសារ | ២- មិត្តភក្តិ |
| ៣-គ្រូបង្រៀន គណៈគ្រប់គ្រង និងសាលារៀន | ៤- សាសនា |
| ៥- បរិស្ថានការងារ | ៦- ប្រព័ន្ធផ្សព្វផ្សាយ |
| ៧- អក្សរសិល្ប៍ | ៨- រដ្ឋាភិបាល |
| ៩- ច្បាប់ | |

## ២. ផ្នែកសំខាន់ៗដែលជះឥទ្ធិពលដល់ការអប់រំសីលធម៌

លោកចិត្តវិទូ Verma(1976) បាននិយាយថា ផ្នែកសំខាន់ៗដែលបានជះឥទ្ធិពលលើការកសាងឥរិយាបថកុមារមាន ២ ផ្នែកគឺ :

### ក- បុគ្គលិកលក្ខណៈខ្លួនឯង

បរិស្ថានបុគ្គលិកលក្ខណៈខ្លួនឯងរួមមាន :

**ក១. វ័យ**

វ័យ ជាកត្តាមួយដែលផ្តល់ឥទ្ធិពលលើកុមារក្នុងការបញ្ជ្រាបឥរិយាបថល្អ មិនល្អ និងការលូតលាស់ទំរង់រូបរាងកាយ ហើយនាំមកជាបណ្តើរៗនូវតំលៃ និងសោភ័ណ។ ឥទ្ធិពលនៃវ័យទៅលើការអភិវឌ្ឍសីលធម៌របស់កុមារត្រូវបានបង្ហាញតាមរយៈការស្រាវជ្រាវរបស់ ÷

- លោក Thompson (1949) ចិត្តវិទូអាមេរិកបានសន្និដ្ឋានថា កុមារមានអាយុ ១១ឆ្នាំទទួលការបញ្ជ្រាបបានច្រើនពីតំលៃមូលដ្ឋាន ។
- លោក Sinha ចិត្តវិទូចិនបានសិក្សាលើបញ្ញត្តិសីលធម៌ និងអសីលធម៌របស់កុមារ ។ កុមារមានអាយុចន្លោះពី ៥ ទៅ ៨ឆ្នាំមានការទទួលចំណេះដឹងកើនឡើងជាងទស្សនវិស័យរបស់បុគ្គលដទៃទៀត នៅក្នុងស្ថានភាពរំភើបចិត្ត បន្ទាប់ពីសិរិតសំរាំងចំលើយពីពួកគេ។ កុមារអភិវឌ្ឍបញ្ញត្តិសីលធម៌ចំពោះសេចក្ដីថ្លៃថ្នូរផ្នែកសុខភាព និងឥរិយាបថ សីលធម៌ គុណធម៌ ដែលរាប់បញ្ចូលភាពស្មោះត្រង់ ការគោរពគ្រូបង្រៀន ឪពុកម្ដាយ អំពើអហិង្សា សេចក្ដីអាណិតអាសូរឆ្ពោះទៅរកជីវិតរស់នៅប្រចាំថ្ងៃ។ កុមារបានបង្ហាញថា ភាពអសីលធម៌រួមមាន : ការលួច ការកុហក ការវាយតប់ ការមិនស្ដាប់បង្គាប់ឪពុកម្ដាយ និងគ្រូបង្រៀន ។
- លោក Eberhart ចិត្តវិទូអង់គ្លេស (1942) តាមរយៈការស្រាវជ្រាវដ៏សមរម្យ និងការសង្កេតលើកុមារអាមេរិកបានរកឃើញដំបូងគេនូវសម្បទាល្អ គឺសីលធម៌ គុណធម៌។

**ក២. <u>បញ្ញា</u>**

ការសិក្សាបានចង្អុលបង្ហាញថា ទំនាក់ទំនងរវាងសីលធម៌ និងបញ្ញា គឺ គ្មានការកំណត់ និងគ្មានទីបញ្ចប់ទេ។

- លោក Jones (1954) គរុវិទូអាមេរិកបានប្រកាសថា អំណាចនៃការរើសអើងរបស់កុមារ គឺមិនផ្អែកលើកំរិតគុណភាពនៃបញ្ញាទេ ។
- លោក Verma (1975) ទស្សនវិទូអ៊ីតាលីបានអះអាងថា គឺគ្មានទំនាក់ទំនងដ៏មានប្រយោជន៍រវាងអំណាចនៃការរើសអើងសីលធម៌ និងបញ្ញា ។ ការស្រាវជ្រាវលើប្រាជ្ញាកុមារបានបង្ហាញថា កុមារមានប្រាជ្ញា មានភាពល្អប្រសើរក្នុងសេចក្ដីស្មោះត្រង់ក្នុងការប្រៀបធៀបមធ្យមភាគបញ្ញាកុមារ។ ម្យ៉ាងវិញទៀត វាមានលក្ខណៈច្បាស់លាស់ កុមារដែលមានប្រាជ្ញាមិនងាយបង្ហាញនូវភាពគំរោះគំរើយទេ ។ បញ្ញាកុមារ គឺជាការស្គាល់ "ចរិយាមារយាទត្រឹមត្រូវជាបញ្ញា មារយាទសាមញ្ញ វាជាភាពសមរម្យចំពោះខ្លួនគេ ដើម្បីអនុវត្តរួមជាមួយការគិតស្មានរបស់ក្រុម ។

**ក៣. <u>ភេទ</u>**

អ្នកស្រាវជ្រាវខ្លះ តាមរយៈពន្លឺលើឥទ្ធិពលនៃបុគ្គលិកលក្ខណៈផ្នែកភេទបានប្រាប់ថា ការអភិវឌ្ឍសីលធម៌សិស្ស ការសិក្សាបានផ្ដល់ភស្ដុតាងជាច្រើននូវភាពផ្សេងគ្នានៅក្នុងលំនាំគំរូនៃគុណធម៌របស់កុមារា និងកុមារី ។ កុមារាមានភាពច្រងេងច្រងាង និងការមិនគោរពវិន័យច្រើនជាងក្មេងស្រី (Henry 1975, Tuma 1960) ពួកគេមិនសុខចិត្តគោរពចំពោះមុខច្បាប់ និងបទបញ្ញត្តិរបស់អាជ្ញាធរ ។

(នៅមានត)

អនុបណ្ឌិត ឡូយ សុខុខាន

# វិធីបង្រៀន និងកម្មវិធី សៀវភៅសិក្សាភាសាខ្មែរ នៅបឋមសិក្សាបំពេញវិជ្ជា ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០

## ១-ស្ថានភាពខ្លះៗ និងភាសាខ្មែរ

ក្រោយពេលឯករាជ្យថ្ងៃ ៩ វិច្ឆិកា ១៩៥៣ ប្រទេសខ្មែរក៏ចាប់រីកលូតលាស់ស្គុះស្គាយ ហាក់ដូចជាមានទឹកអម្រឹតបង្ហូរចុះមកស្រោចស្រពទឹកដីដែលហួតហែងរីងរៃអស់កាលជាច្រើនសតវត្សមកហើយ ។ សមិទ្ធផលធំៗគ្រប់វិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បានផុសឡើងត្រដែត គ្រប់ទិសទីពាសពេញព្រះរាជាណាចក្រកម្ពុជា ។ នៅពេលនោះ សន្ទុះចិត្តសប្បាយរីករាយចំពោះការរៀនសូត្ររបស់ប្រជាពលរដ្ឋមានទំហំធំធេងណាស់ ។ គ្រប់ស្រុក គ្រប់ឃុំមានសមាគមទ្រទ្រង់សាលារៀនបង្កើតដោយព្រះសង្ឃ និងមាតាបិតាសិស្ស ។ គេនាំគ្នាធ្វើបុណ្យផ្ការៃបច្ច័យមកកសាងសាលារៀននៅក្នុងភូមិ ឃុំរបស់ខ្លួនទាំងបឋមសិក្សា ទាំងមធ្យមសិក្សា បានរីកដុះដាលដូចផ្សិតត្រូវទឹកភ្លៀង ។ ដើម្បីឆ្លើយតបនឹងតម្រូវការគ្រូបង្រៀន ក្រសួងអប់រំបានបង្កើតមជ្ឈមណ្ឌលគរុកោសល្យទន្លេបាទីនៅឆ្នាំ១៩៥៥ មជ្ឈមណ្ឌលគរុកោសល្យកំពង់កន្ទួតនៅឆ្នាំ ១៩៥៧ និងវិទ្យាស្ថានជាតិគរុកោសល្យនៅឆ្នាំ១៩៥៨ ។ មជ្ឈមណ្ឌលគរុកោសល្យ និងវិទ្យាស្ថានគរុកោសល្យទាំងនេះ បានបណ្តុះបណ្តាលគ្រូជាច្រើនជំនាន់រហូតដល់មុនឆ្នាំ ១៩៧៥[១] ។

ទន្ទឹមនឹងនោះដែរ ថវិកាជាតិដែលផ្តល់ទៅអោយក្រសួងអប់រំដោយរាជរដ្ឋាភិបាល មានការកើនឡើងយ៉ាងខ្លាំង គឺកើនពី ១២,២៨ភាគរយនៅឆ្នាំ១៩៥៤ ដល់ ២២,៥៦ភាគរយនៅឆ្នាំ១៩៥៨ ហើយនិង ២១,៨១ នៅឆ្នាំ១៩៦៨ ។ ថវិកានេះ ភាគច្រើនបានធ្លាក់ទៅលើការចំណាយចំពោះបុគ្គលិកសិក្សា ។ ឯចំណាយទៅលើសម្ភារៈមានចំនួនតិចតួចទេ គឺមានប្រហែល ៣ ទៅ ៤ ភាគរយ ។ ប្រការនេះហើយ ដែលធ្វើអោយប្រាក់បៀវត្សបុគ្គលិកសិក្សាបានកើនឡើងខ្លាំងទៅតាមនោះដែរ ។ ឧទាហរណ៍ដូចជាសាស្ត្រាចារ្យមធ្យមសិក្សាថ្នាក់លេខមួយដែលមានភរិយា និងកូន៤នាក់ត្រូវទទួលបានប្រាក់ប្រចាំឆ្នាំ ១៥០ ៦០០រៀល ក្នុងមួយឆ្នាំ ក្នុងនោះរាប់បញ្ចូលទាំងប្រាក់បៀវត្សប្រចាំឆ្នាំ៧៧ ៤០០រៀល ប្រាក់ចំណាយគ្រួសារ ២៥ ២០០រៀល ប្រាក់លំនៅដ្ឋាន ២៤០០០រៀល និងប្រាក់កោសលាភ គរុកោសល្យ ២៤ ០០០រៀល ។ អធិការបឋមសិក្សាថ្នាក់លេខ ៣ ដែលមានភរិយា និងកូន៦នាក់ក្នុងបន្ទុកត្រូវទទួល បានប្រាក់បៀវត្សប្រចាំឆ្នាំ ៥៨ ៥០០រៀល ប្រាក់បំណាច់គ្រួសារ ៣៤៨០០រៀល ប្រាក់លំនៅដ្ឋាន ២៤ ០០០ និងប្រាក់ កោសលាភគរុកោសល្យ ១៨ ០០០រៀល សរុបទៅគាត់ត្រូវបានប្រាក់សរុប ១៣៥ ៣០០រៀល ។ គ្រូបឋមសិក្សា លេខ ២ ដែលមានភរិយា និងកូន៥នាក់នៅក្នុងបន្ទុកត្រូវបានប្រាក់បៀវត្សប្រចាំឆ្នាំ ៤៨ ០០០ ប្រាក់ចំណាយគ្រួសារ ៣០ ០០០រៀល និងប្រាក់កោសលាភគរុកោសល្យ ១២ ០០០រៀល សរុបទៅគាត់ ត្រូវទទួលបានប្រាក់ ៩០ ០០០ រៀលក្នុងមួយឆ្នាំ[២] ។ យោងតាមរបាយការណ៍ខាងលើនេះ បញ្ជាក់ថាជីវភាពរបស់គ្រូក្នុងសម័យនោះមានកម្រិតខ្ពស់។ ប្រការនេះហើយដែលធ្វើអោយសម័យនោះ មានមុខរបរតែមួយគឺបង្រៀន និង

(១)សូមមើល ស៊ិន សំណាង និងយ៉ង់ ធី : ប្រវត្តិនៃការអប់រំបឋម និងមធ្យមសិក្សានៅកម្ពុជាពីបុរាណកាលរហូតដល់បច្ចុប្បន្នកាល ១៩៩៨-៩៩ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធឆ្នាំ ១៩៩៩ ទំព័រ ៣៣

(២)សូមមើល ស៊ិន ជន : របាយការណ៍ស្តីពីហិរញ្ញប្បទាន និងថវិកាអប់រំជាតិភ្នំពេញ មហាវិទ្យាល័យគរុកោសល្យ មណ្ឌលអប់រំអធិការបឋមសិក្សា ឆ្នាំសិក្សា ១៩៧២-៧៣ ទំព័រ ១៣-២១

អប់រំសិស្សតែម្យ៉ាងគត់។ មនសិការវិជ្ជាជីវៈគាត់ខ្ពស់ប្រឹងប្រែងបង្រៀន និងអប់រំសិស្សអស់ពីសមត្ថភាពធ្វើអោយសមត្ថភាពសិស្សក៏ប្រសើរទៅ តាមនោះដែរ ។

ក្នុងវិស័យសិក្សាតែម្យ៉ាងគត់ បើតាមស្ថិតិជាសារវន្តសម្រាប់ឆ្នាំ ១៩៦៩ បានអោយដឹងថា មានសាលាបឋមសិក្សាចំនួន៥ ៨៥៧កន្លែង មានសិស្សចំនួន១ ០២៥ ០០០នាក់ ។សាលាមធ្យមសិក្សាចំនួន១៨០កន្លែង មានសិស្សចំនួន១១៧ ០០០នាក់ ។ សាកលវិទ្យាល័យ ៩កន្លែង និងមាននិស្សិត ១០ ៨០០នាក់ ។ សាលាបច្ចេកទេស ឬវិជ្ជាជីវៈ៩៩ កន្លែង មានសិស្ស ៧ ៤០០នាក់ ។ សរុបទៅឃើញថា មានសិស្សដល់ទៅចំនួន ១ ១៦១ ០០០នាក់ ។

ទាំងនេះសបញ្ជាក់អោយឃើញថា សាលាបឋមសិក្សាបានកើនចំនួនទ្វេគុណ ឬត្រីគុណ ដើម្បីរៀបចំអប់រំពលរដ្ឋថ្មីស្រង់ពលរដ្ឋនេះអោយចាកផុតពីភាពល្ងង់ខ្លៅអាប់អួរ ។ មធ្យមសិក្សាក៏ដុះកើតកាលវាលគុម្ពបើកទ្វារអោយកូនចៅអ្នកស្រុកទៅរៀបចំខ្លួនបំរើប្រទេសជាតិអោយបានយ៉ាងមានប្រសិទ្ធភាព ។ ឧត្តមសិក្សាដែលកាលសម័យមុនឯករាជ្យគ្មានសោះក៏ផុសឡើងដែរ ដើម្បីដឹកនាំយុវជនខ្មែរឆ្ពោះរកជម្រៅនៃការសិក្សាអប់រំខាងវិជ្ជាជីវៈ បច្ចេកទេស ធ្វើពលរដ្ឋអោយមានប្រយោជន៍ដល់សង្គមជាតិ[៣] ។

ក្នុងថ្នាលឯករាជ្យនយោបាយ និងឯករាជ្យសេដ្ឋកិច្ច វប្បធម៌ជាតិ ក៏ចាប់រីកស្គុះស្គាយឡើងវិញដែរ ភាសាជាតិក៏ងើបមុខមកបំរើសេចក្ដីត្រូវការជាថ្មី ផ្សាយវប្បធម៌ជាតិអោយទាន់តាមចង្វាក់នយោបាយ និងសេដ្ឋកិច្ចនៃកម្ពុជាទំនើប ។

សន្សឹមៗតែប្រាកដ ភាសាជាតិបានចូលមកជំនួសភាសាបរទេស ។ យើងបានដឹងហើយថា នៅសម័យអាណានិគមបារាំង អក្សរសាស្ត្រខ្មែរបានចុះដល់ក្រោមសូន្យ គម្ពីរ សាស្ត្រា សៀវភៅក្បួនខ្នាតផ្សេងៗដែលកត់ត្រាសរសេរជាអក្សរខ្មែរត្រូវរត់ទៅជ្រកពួនក្រោមម្លប់បារមីនៃព្រះសង្ឃ និងទីវត្តអារាមនានានៅពេញផ្ទៃប្រទេស ។ ការប្រើប្រាស់អក្សរខ្មែរត្រូវបានបារាំងហាមឃាត់ជាផ្លូវការ ដោយជំនួសមកវិញនូវអក្សរឡាតាំង ពោលគឺបារាំងបង្ខំអោយខ្មែរសរសេរភាសាខ្មែរដោយប្រកបតាមបែបអក្សរឡាតាំងវិញ ដែលសូម្បីតែសារពត៌មានខ្មែរខ្លះ ក៏ត្រូវចេញ ផ្សាយជាអក្សររ៉ូម៉ាំងហៀវដែរ ។

នៅពេលនេះ ដោយឃើញចាប់នឹងអំពើរលោភលន្លានពានដ៏ធ្ងន់ធ្ងររបស់បារាំង ជាពិសេសគឺការលុបបំបាត់អក្សរសាស្ត្រខ្មែរ អាចារ្យ ហែម ចៀវ បានរួមគ្នាជាមួយនឹងអ្នកស្នេហាអក្សរសាស្ត្រជាតិ បានក្រោកឡើងតស៊ូប្រឆាំង ប៉ុន្តែការតស៊ូនេះត្រូវបរាជ័យហើយអាចារ្យ ហែម ចៀវ ត្រូវបានបារាំងចាប់ខ្លួននៅថ្ងៃទី ១៧ កក្កដា ឆ្នាំ ១៩៤២ ហើយបានបញ្ជូនទៅកោះត្រឡាច ក្រោយមកលោកក៏បានទទួលមរណភាពនៅទីនោះ នៅចុងឆ្នាំ១៩៤៣ ក្នុងជន្មាយុ ៤៥ឆ្នាំ[៤] ។

នៅក្នុងសមាជជាតិលើកទី ២៣[៥] ក្រោមព្រះរាជតិរះដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះ នរោត្តម សីហនុ បានអនុម័តយ៉ាងឱឡារិក យកភាសាខ្មែរមកជំនួសភាសាបារាំងក្នុងកិច្ចការរាជការ ហើយជាពិសេសក្នុងសិក្សាធិការជាតិភស្តុតាងដ៏ជាក់ស្ដែងមួយទៀតនៃឯករាជ្យវប្បធម៌កើតចេញពីឯករាជ្យនយោបាយ ។ គ្រប់ពេល និងគ្រប់ទីសម្ដេចព្រះនរោត្តម សីហនុជាព្រះគំរូដ៏ចំបងក្នុងការនិយមភាសាជាតិ ។ ពាក្យថ្មីៗ ពិបាកៗក្លាយទៅជាមានលក្ខណៈប្រជាប្រិយយ៉ាងរហ័សដោយសារតែព្រះអង្គ ។ ព្រះកាយវិការដ៏ខ្ពស់នេះ ជាផ្លេកបន្ទោរចិញ្ចែងចូលទៅដាស់សតិអារម្មណ៍និយមនៅគ្រប់ទីកន្លែង ។ រដ្ឋសភាប្រើភាសាខ្មែរជា

(៣) សូមមើលក្រសួងអប់រំជាតិ : ឯករាជ្យជាតិ និងភាសាជាតិ នៅក្នុងទស្សនាវដ្ដីខេមរយានកម្មក្នុងការសិក្សាលេខ២ ខែវិច្ឆិកា ឆ្នាំ១៩៦៨ទំព័រ៥-៦

(៤) សូមមើលឈៀង វិបុល : ប្រវត្តិក្បាលនៃភាសានិងអក្សរសាស្ត្រខ្មែរ នៅក្នុងទស្សនាវដ្ដីប្រជាប្រិយលេខ២៣១ ថ្ងៃទី ១១-២០ ខែកុម្ភៈ ឆ្នាំ ២០០៣ ទំព័រ៧៦

(៥) សមាជជាតិលើកទី ២៣ ធ្វើនៅថ្ងៃទី ១០-១៣ ខែកក្កដា ឆ្នាំ១៩៦៧ ។

ផ្លូវការក្នុងការពិភាក្សាបញ្ហាស្រុកទេស ។ កងទ័ពអោយបញ្ជាជាខ្មែរ ។ ក្រុមកសិកម្មខំផ្សាយបច្ចេកទេសទំនើបជាខ្មែរ ។ ក្រសួងពេទ្យផ្សាយវិធីអនាម័យ និងការពាររោគជាភាសាជាតិ ។ សារពត៌មាន ទស្សនាវដ្ដី ចេញផ្សាយព្រោងព្រាតជាភាសាខ្មែរ ។ ខាងវិស័យសិល្បៈ វប្បធម៌ ក៏រីកចំរើនឥតគណនា ភាពយន្ត ប្រលោមលោក ល្ខោន ក្បួនតម្រា សុទ្ធតែប្រើភាសាជាតិទាំងអស់ ។

យុវជន ពលរដ្ឋ ទាំងក្មេង ទាំងចាស់ ខំស្ទុះស្ទារករៀន រកយល់ភាសាជាតិអោយរឹតតែបានច្បាស់ ។ មហាវិទ្យាល័យអក្សរសាស្ត្រ ផលនៃឯករាជ្យជាតិបានស្រាវជ្រាវ និងផ្សាយចំណេះជាភាសាខ្មែរ ពុទ្ធិកមហាវិទ្យាល័យ ផ្សាយលទ្ធិសាសនា ទ្រឹស្ដីទស្សនវិជ្ជាជាខ្មែរ ។ សកលវិទ្យាល័យប្រជារាស្ត្រ អប់រំក្របខណ្ឌបច្ចេកទេសជាខ្មែរ ។ ការស្រាវជ្រាវរចនាតុបតែង ផ្សាយសិល្បៈពីខាងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សុទ្ធសឹងជាភាសាខ្មែរទាំងអស់ ។ សន្ទុះថ្មីមួយទៀតកើតមានឡើងជាប់ជាមួយសមិទ្ធិដ៏ប្រសើរវិសេសនេះ ។ ជនបរទេសដែលរស់នៅក្នុងប្រទេសចាប់ភ្ញាក់ សតិអារម្មណ៍ចំពោះភាសាខ្មែរ ខំស្វះស្វែងរៀនសូត្រភាសា អក្សរសាស្ត្រខ្មែរសម្របតាមចលនាអក្ខរកម្ម ។

ក្នុងរយៈពេលឯករាជ្យជាតិក្នុងប្រទេសខ្មែរ វប្បធម៌ខ្មែរ ភាសាខ្មែរបានរីកធំធាត់ប្រែរូបចេញពីរខេករខាកមកធ្វើជាភាសារឹងប៉ឹងមាំមួន មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ល្មមបំរើសេចក្ដីត្រូវការថ្មីនៅកម្ពុជា ។ ក្នុងវិស័យនេះ យើងមានភ័ព្វសំណាងធំមួយ ដោយមានអ្នកប្រាជ្ញចំបងខាងភាសា គឺសម្ដេចសង្ឃរាជថ្នាក់ទី១ ដែលទ្រង់ជាឃ្លាំងគម្ពីរនៃភាសាខ្មែរ ។ ព្រះអង្គទ្រង់ឥតមានសំចៃព្រះកាយពលក្នុងការចងក្រងក្បួនខ្នាតបង្កើតពាក្យពេចន៍ថ្មី ដើម្បីញ៉ាំងភាសាអោយរស់រានទាន់សម័យវិទ្យាសាស្ត្រនឹងគេ ស្របតាមព្រះរាជនយោបាយសម្ដេចនរោត្ដម សីហនុ ។

ការនិយមភាសាជាតិក្នុងកិច្ចការរាជការ ក្នុងសាលា មានន័យថា ផ្សាយវិជ្ជាបច្ចេកទេសទំនើបអោយជ្រួតជ្រាបបានយ៉ាងរហ័សដល់ប្រជាពលរដ្ឋ មានន័យម៉្យាងទៀតថា ចំរើនដល់សេដ្ឋកិច្ចជាតិ និងកិរិតវប្បធម៌នៃអ្នកស្រុក(៦) ។

ក្នុងរយៈពេលឯករាជ្យនេះ ប្រជាជាតិខ្មែរបានងើបផុតពីភាពអាប់អួរនៃសម័យចាស់ ប្រជាជាតិខ្មែរ សេដ្ឋកិច្ចខ្មែរ បានរីកលូតលាស់ឥតឈប់ឈរ ខាងភាសាជាតិ និងវប្បធម៌ ក៏រីកចំរើនខ្លាំង ។ ក្នុងន័យដូចគ្នានេះ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានព្រះរាជបញ្ជាអោយចារឹកទុកលើផ្ទាំងសិលា មន្ទីរពេទ្យព្រះបាទជ័យវរ្ម័នទី ៧ គាថា ៤៨ ថា : "ស្នាព្រះហស្ដដ៏ល្អល្អះដែលខ្ញុំបានស្ថាង គប្បីអ្នករក្សាទុក ដ្បិតវាជាស្នាដៃរបស់អ្នកផងដែរ..." ។

(នៅមានត)

អនុបណ្ឌិត ស្វ ស្វធីរ

---

(៦) សូមមើលក្រសួងអប់រំជាតិ : ឯករាជ្យជាតិ និងភាសាជាតិ ជ.ឯ.ម ទំព័រ ៦-៧ ។

និងបទវិគ្រោះ :

*ឧទាហរណ៍:*

- ហនតីតិ > ឃាតកោ (ជនោ)
- ឃាតំ ករោតីតិ > ឃាតករោ (ជនោ)... ។

ប៉ុន្តែពាក្យខ្លះ ចុះ ណ្-បច្ច័យ មិនបានទេ ពីព្រោះពាក្យនៅខាងដើមនោះ ជាសន្ទុបបទ មិនមែនជាពួកធាតុ ត្រូវប្រើ អ-បច្ច័យវិញ ទើបបាន ។

ឧទាហរណ៍ : ពិធីករ, កសិករ, កម្មករ... មិនអាចសរសេរជា ពិធីក, កសិក, កម្មក... បានទេ ពីព្រោះ ពិធី, កសិ, កម្ម... ជានាម ។

(នៅមានត)

លោក លី សុធីរ

## អន្លង់ជ្រៅៗនៃមហាសមុទ្រ

មហាសមុទ្រប៉ាស៊ីហ្វិក :

| | | |
|---|---|---|
| + ម៉ារីយ៉ាន | (Mariannes) | : ១១ ០៣៤ម |
| + តុងហ្គា | (Tonga) | : ១០ ៨៨២ម |
| + គូរីល | (Kouriles) | : ១០ ៥៤២ម |
| + ហ្វីលីពីន | (Philippines) | : ១០ ៥៤០ម |
| + បូណាំង | (Bonin) | : ១០ ៣៤០ម |
| + កែម៉ាដេច | (Kermadec) | : ១០ ០៤៧ម |
| + នូវែលប្រឺតាញ | (Nouvelle-Bretagne) | : ៩ ១៤០ម |

មហាសមុទ្រអាត្លង់ទិច:

| | | |
|---|---|---|
| + ព័រតូរីកូ | (Porto-Rico) | : ៩ ២១៨ម |

មហាសមុទ្រឥណ្ឌា:

| | | |
|---|---|---|
| + ជ្វា | (Java) | : ៧ ៤៥៥ម |

# គំនូរ

## វិធីបង្រៀនគំនូរ (ត)

ដោយលោក : ប៉ាន់ ត្រា

### ផ្ចាំង និងខ្សែតុបតែងលំអ

**ក-  ផ្ចាំងតុបតែងលំអ...**

**ខ-  ខ្សែតុបតែងលំអ**

ផ្ចាំងតុបតែងលំអក្នុងផ្ទៃការេខាងលើនេះ បើគេយកផ្ចាំងណាមួយមកផ្ចិតដាក់តំរៀបបន្តគ្នាអោយស្មើគ្នាបន្តគ្នាវែងទៅ គេនឹងបានជាខ្សែតុបតែងលំអដ៏មានសោភ័ណភាពគួរអោយគយគន់ ។

ខាងក្រោមនេះ គឺខ្សែតុបតែងលំអ ដែលកើតបានឡើងដោយយកផ្ចាំងលំអក្នុងផ្ទៃការេខាងលើមកតំរៀបបន្តគ្នា។

(ដាក់ពណ៌)



## គ. ខ្សែតុបតែងលំអដោយរូបភាព

រូបភាពផ្សេងៗដែលសិស្សបានគូររួចហើយ ដូចជារបស់ប្រើប្រាស់ ស្លឹកឈើ ផ្កាឈើ សត្វទ្វេបាទ-ចតុបាទ មនុស្ស ។ល។ គេយកមកគូរជាផ្ទាំងតុបតែងលំអក្នុងផ្ទៃការេ ហើយផ្ដិតតំរៀបគ្នាអោយស្មើបន្តជាខ្សែវែងទៅ គេនឹងបានជាខ្សែតុបតែងលំអគួរអោយគយគន់ ។

ឧទាហរណ៍ :

(ដាក់ពណ៌)



(នៅមានត)




## បណ្ដាំអ្នកម្ដាយ

(បទពាក្យ ៧)

មនុស្សសត្វក្នុងលោកកើតមកហើយ    កុំគិតសោះឡើយថាគ្មានម្ដាយ
បង្កើតអារម្មណ៍រូបរាងកាយ    មនុស្សសត្វទាំងឡាយមានប្រុសស្រី ។
អ្នកម្ដាយពរបុត្រក្នុងឧទរ    រាល់ពេលដើរឈរមិនដែលស្ដី
ឈឺចាប់ក្នុងប្រាណមិនថាអ្វី    ពេញចិត្តមិនថ្វីព្រោះបុត្រភ្ញារ ។
ពេលចាកទ្រូងមាសថ្ងៃអស្ចារ្យ    ជីវិតសង្ខារនៅមាត់ទ្វារ
មច្ចុរាជចាំឆក់គ្រប់វេលា    អោយតែពុំងាកូនបានរស់ ។
ទារក-រិកានៅក្មេងខ្ចី    ត្រូវការថ្នមបីដោយសរស្មោះ
អ្នកម្ដាយបំបៅនឹងទឹកដោះ    លោហិតហូរស្រស់ចាកទ្រូងថ្លៃ ។
ពេលយប់មិនស្កប់នឹងដំណេក    ទោះដើរឬដេកគិតមមៃ
កូននៅពីតូចនៅក្នុងផ្ទៃ    គ្មានអ្នកដទៃណាជួយថ្នម ។
សន្ទិយាស្ងប់ស្ងាត់បាត់សម្លេង    វាយោជាភ្លេងក្នុងអារម្មណ៍
សំលេងកូនតូចលាន់រងំ    អ្នកម្ដាយច្រៀងថ្នមលោមបំពេរ ។
កូនអើយគេងទៅពៅមាសម្ដាយ    អនិច្ចារូបកាយណាមាសមេ
ដល់កូនធំឡើងគិតគ្មាន់គ្នេរ    លកលែរិះរេច្នៃអោយហើយ ។
ភ្លៅម្ដាយទាំងគូធ្វើជាពូក    ដៃម្ដាយសណ្ដូកធ្វើជាខ្នើយ
ទាំងដៃទាំងជើងអោយកូនកើយ    កូនកុំកន្ដើយខំសិក្សា ។
ទ្រូងម្ដាយរន្ធត់ញាប់ញ័រញាក់    ព្រឺព្រួចកន្ត្រាក់អស់អង្គា

ត្រមង់ត្រមោចរស់ឯកា វេទនាស្លាប់បាសល់តែឆ្អឹង ។
ជាតិនេះតឹកម្មតាមផ្ដន្ទា លួចយំរងាកាយកំព្រឹង
មានតែរូបកូនជាទីពឹង អោយម្ដាយននឹងតទៅមុខ ។
អ្នកកុំធ្វើអោយម្ដាយត្រាំត្រា ព្រោះប្រុសពុំងារស់មិនសុខ
កុំដើរបោទ្បែប្រែនាំទុក្ខ ញ៉ាំញីបុករុកឈ្លីក្ដៅផ្សារ ។
គ្រឿងញៀនបំពាននាំរងទុក្ខ ពាលាគ្រប់មុខល្បែងស្រីស្រា
នាំរោគចំលងអេដស៍ឬស្យា ប្រល័យសង្ខារក្ស័យជីពជន្ម ។
មិនបានបំរើប្រទេសជាតិ រវល់តែឆ្លៀតគិតគួរគន់
ព្យាបាលអាត្មាខ្លាចស័យស័ន់ តែក៏មិនធន់ត្រូវស្លាប់ទៀត ។
ម្ដាយផ្ញើបណ្ដាំតាមខ្យល់បក់ រឿងរ៉ាវអាក្រក់កូនកុំបៀត
ស្រលាញ់សិក្សាការពារជាតិ កុំអោយរវាតពីផ្លូវល្អ ។
ព្រះពុទ្ធោវាទញាតិកុំភ្លេច ខំប្រឹងខ្ជប់វេចដោយកំរ
ចារទុកក្នុងចិត្តត្បិតលោកក្រ ការកូនចៅត ឆ្លងវាលបី ។
វាលនេះហៅមហាធំពន់ពេក ជនច្រើនអនេកទាំងប្រុសស្រី
ឆ្លងមិនផុតជីវិតក្រក្រី ចរណៃគប្បីជៀសអោយបាន ។
ខំសាងក្ដីសុខរស់ប្រពៃ ក្រោមពោធិត្រឈៃប្រសើរថ្កាន
រួមរូបជួបជុំសុខសាន្តក្រាន ញាតិផៅសន្ដានបានសុខា ។

លោកស្រី ឈឹម ចន្ទតារា

អធិការបឋមសិក្សា

---

## ប្រស្នាល្បងប្រាជ្ញា

១- ក្នុងបណ្ដាព្យញ្ជនៈទាំង ៣៣ តួ តើព្យញ្ជនៈណាដែលមានភព្វសំណាងជាងគេ ហើយព្យញ្ជនៈណាដែលអភ័ព្វជាងគេ?

២- មួកមួយថ្លៃ 198 រៀល តើមួកនោះរាងដូចម្ដេច?

ចំលើយនៅទំព័រទី ៤៦

ផាត់ សាំ

# ភ្នំចង្ក្រានរយ

ភ្នំចង្ក្រានរយជាភ្នំតូចមួយនៃចង្កោមភ្នំចន្ទក្រហម ។ អ្នកស្រុកសៀមរាប សូម្បីតែអ្នករស់នៅភូមិដូនឯម ឃុំគោកដូង ស្រុកអង្គរធំ ដែលជាទីតាំងរបស់ភ្នំនេះក្តី ក៏ពុំសូវមាននរណាស្គាល់ជាក់ស្តែងដែរ។ មានមនុស្សអាយុស្របាល ៥០ឆ្នាំ ២-៣នាក់ធ្លាប់ឡើងទៅរកថ្នាំសង្កូវនៅទីនោះ ក្នុងនោះមានលោកពូភឿន ភិនដែល បានស្គាល់ច្បាស់ ។

បច្ចុប្បន្ននេះ គេបានស្គាល់ឈ្មោះភ្នំនេះជាច្រើននាក់ដោយសារមានផ្លាកឈ្មោះទីផ្សារមួយនៅឃុំពាក់ស្នែងតាមបណ្តោយផ្លូវវ៉ារិន "ផ្សារចង្ក្រានរយ" ដែលស្ថិតខាងត្បូងភ្នំនោះចំងាយ១០គីឡូម៉ែត ជាទីផ្សារដែលសហគ្រាសផលិតស្បៀងជីវី-តិច សហការជាមួយរដ្ឋអំណាចគ្រប់លំដាប់ថ្នាក់របស់ខេត្តសៀមរាប បានស្ថាបនា និងដាក់អោយប្រើប្រាស់កាលពីដើមឆ្នាំ២០០៤ (ពិធីបើកទីផ្សារ ក្រោមអធិបតីភាពលោកអភិបាលស្រុកអង្គរធំ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៥) ។ ការស្ថាបនាទីផ្សារនេះក៏គឺជាកម្មវិធីការងាររបស់ស្រុកអង្គរធំ ហើយការបំពាក់ផ្លាកបែបនេះ ព្រោះមានគោលបំណងចង់អោយភ្នំនេះរស់ឡើងវិញ ។ វាជាគំរោងអាទិភាពរបស់ស្រុកក្នុងការអភិវឌ្ឍតំបន់ ។ សព្វថ្ងៃ សហគ្រាសអាជីវកម្មថ្មមួយបានបោះទីតាំងនៅជិតភ្នំនោះហើយ នៅប្រមាណ៤០គីឡូម៉ែតពីទីរូមខេត្ត នៅត្រង់ទីតាំងមួយគួរចាប់អារម្មណ៍ ដែលអ្នកស្រុក អ្នកភូមិ ពិសេសកុមារតែងនាំគ្នាជិះកង់ឡើងទៅលេងកំសាន្តនឹង "ទឹកខួប" (ល្អាងទឹកនឹង មិនហូរ) មួយមានទឹកខួបប្រាំងវស្សា ទឹកថ្លាដូចកញ្ចក់ត្រជាក់ស្រេង ក្លិនឈ្ងុយពិដោរនៃជ័រឈើ (សំរាប់ធ្វើតំរងធម្មជាតិច្រោះចុងក្រោយក្នុងការផលិតទឹកបរិសុទ្ធ) ។



ទិដ្ឋភាពជាក់ស្តែង នៅត្រង់ម្តុំ "ទឹកខួប" ក៏ជាទិដ្ឋភាពគួរចង់គយគន់ អ្នកមិនស្គាល់ភ្នំចង្ក្រានរយច្បាស់ជាយល់ថា ភ្នំនេះហើយជាភ្នំចង្ក្រានរយ ព្រោះនៅទីនេះមានផ្ទាំងសិលារៀបរយ ប្រៀបដូចជាខ្ទះធំៗកំពុងដាក់ចំហុយអ្វី ។



មកដល់ត្រង់នេះ យើងត្រូវធ្វើដំណើរទៅកាន់ភ្នំចង្ក្រានរយដោយជើងប្រវែង១០គីឡូម៉ែតទៀត ។ បើគិតពីទីរួមខេត្តសៀមរាប មានចំងាយ៥០គីឡូម៉ែត ។

បើគេចង់ទៅកាន់ភ្នំចង្ក្រានរយ ត្រូវចេញដំណើរពីផ្លូវចូលភ្នំត្រង់សាលាបឋមសិក្សាគោកភ្លៅ ពីម៉ោង៧ព្រឹករហូតដល់ម៉ោង២រសៀលទើបដល់។ បើអ្នកមិនធ្លាប់ស្គាល់ភ្នំនោះទេ ច្បាស់ជាវង្វេងទៅរកភ្នំផ្សេងៗ ដូចជា ភ្នំបាយដុះ ភ្នំចន្ទក្រហម(ភ្នំមេ) ភ្នំអំពិល ភ្នំជ័រ ភ្នំម្រេច ភ្នំព្រៃបាំង ភ្នំអន្លែងសព្វព្រលឹង ។ល។ ភ្នំចុងក្រោយនេះ គេ មិនដឹងថាហេតុអ្វីមានឈ្មោះដូចនេះ តែមានរឿងនិទានដំណាលពីព្រាន "ប៊ុន" ដែលទទួលខុសត្រូវតាមរកនាង "ទុន សត្រា" កូនស្រីស្តេចដីរស ។

ដូចនេះ បើចង់ដល់គោលដៅ (ភ្នំចង្ក្រានរយ) ត្រូវតែមានអ្នកនាំផ្លូវ ហើយផ្លូវនោះ ត្រូវចាប់ដើរពីទឹកខួបសំដៅទៅទិសខាងជើង ឆ្លងកាត់ភ្នំបាយដុះ ភ្នំចន្ទក្រហម និងជ្រលងផ្សេងៗ ។

ភ្នំចង្ក្រានរយ ជាភ្នំល្អាលមួយខ្ពស់ អ្នកមិនធ្លាប់ឡើងចុះភ្នំមិនអាចឡើងបានដោយងាយនោះទេ ។ តែបើដល់កំពូលហើយ នោះគេរីករាយដើរកំសាន្ត ព្រោះជាវាលរាបស្មើ ហាក់ដូចជាព្រលានភស្តុភារមួយយ៉ាងសំបើមនៅទីនោះមានចង្ក្រានរាប់រយរៀបរយដែលសព្វថ្ងៃនេះអ្នកទៅដល់ទីនោះប្រើប្រាស់ចង្ក្រានទាំងនោះ មានម្ជប់ត្រឈឹង ត្រឈៃមានសត្វស្វា ទោចរស់នៅទីនោះយ៉ាងច្រើន មានទឹកលាក់ខ្លួន សំរាប់ផ្គត់ផ្គង់នៅទីនោះផងដែរ ។

បើតាមតំរុយខ្លះៗ អ្នកភូមិបានអោយដឹងថា ពីអតីតកាល នៅពេលដែលត្រូវបរាជ័យ មានស្តេចដឹកនាំកំលាំងនៅទីនោះ ដើម្បីឆក់មកកាន់កាប់រាជធានីអង្គរវិញ ព្រោះកន្លែងនោះមានរុក្ខផលច្រើនយ៉ាងដូចជា ម្រេច (ភ្នំម្រេច) ជ័រ (ភ្នំជ័រ) អំពិល (ភ្នំអំពិល) ចន្ទក្រហម (រុក្ខជាតិ) មានអំណោយទានក្នុងការដាំបាយ (ភ្នំបាយដុះ) ខ្មែរតែង

និយាយថា "អង្គរនេះចំណេញណាស់ ដាំបាយឡើង"។ ក្រៅពីនេះយើងអាចកត់សំគាល់បានថា នៅភូមិសាស្ត្រទីនោះមានដីគោកច្រើនកន្លែង ពិសេសទីតាំងភ្នំនេះតែម្តង : ឃុំគោគដូង គោកភ្នៅ...។

យើងមិនបានស្រាវជ្រាវប្រវត្តិការណ៍នៃតំបន់នេះទេ យើងគ្រាន់តែពិចារណាទៅតាមលក្ខណៈអក្សរសិល្ប៍តែប៉ុណ្ណោះ ។ ប្រការនេះ យើងអាចសន្និដ្ឋានបានថា បើតាមលក្ខណៈឈ្មោះខ្មែរនោះពិតជាមានការពិតជាក់ស្តែង តំបន់នេះជាតំបន់ប្រមូលផ្តុំកំលាំងក្នុងបុព្វហេតុណាមួយដែលការងារទាំងនោះត្រូវចាត់តាំងជាសមូហភាពៈបាយរួម (ចង្ក្រានរយ) វាអាចជា ÷

